អង្គការភាពជាដៃគូអប់រំ នៃអង្គការក្រៅរដ្ឋាភិបាល (NEP)

# សន្និសីទជាតិលើកទី៤
# ស្ដីពី
# បរិវត្តកម្មអប់រំដើម្បីលើកកម្ពស់បរិយាបន្នក្នុងវិស័យអប់រំ



រាជធានីភ្នំពេញ

ថ្ងៃពុធ -ព្រហស្បតិ៍ ១១ - ១២ កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ត្រូវនឹងថ្ងៃទី២០-២១ ខែមីនា ឆ្នាំ២០២៤

គាំទ្រ និងឧបត្ថម្ភដោយ

## ១. សេចក្តីផ្តើម

នាថ្ងៃពុធ និងព្រហស្បតិ៍ ១១ - ១២ កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី២០-២១ ខែមីនា ឆ្នាំ២០២៤ អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល បានរៀបចំសន្និសីទជាតិលើកទី៤ ស្តីពី បរិវត្តកម្មអប់រំដើម្បីលើកកម្ពស់បរិយាបន្នក្នុងវិស័យអប់រំ ក្រោមកិច្ចសហការ និងការគាំទ្រថវិកាដោយ ទីភ្នាក់ងារជំនួយអាមេរិក USAID តាមរយៈអង្គការ FHI360, ភាពជាដៃគូសកលសម្រាប់ការអប់រំ (GPE) តាមរយៈ អង្គការអុកស្វាមប្រចាំប្រទេសដាណឺម៉ាក (Oxfam Denmark) គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) អង្គការទស្សនៈពិភពលោកអន្តរជាតិប្រចាំប្រទេសកម្ពុជា (WVI-C) អង្គការ អេដ អេ អាកស្យុង (Aide et Action) អង្គការសហព័ន្ធសាលារៀនពិភពលោក (UWS) និងអង្គការអេពិកអាត (Epic Arts)។

សន្និសីទជាតិលើកទី៤នេះ គឺជាកាតាលីករដ៏សំខាន់មួយដែលជំរុញការសន្ទនា ចែករំលែកការអនុវត្តល្អៗ និងបង្កើតភាពជាដៃគូ ដើម្បីពង្រឹងការអប់រំបរិយាបន្ន ប្រកបដោយសមធម៌ សម្រាប់អ្នកសិក្សាទាំងអស់នៅកម្ពុជា ។ សន្និសីទនេះ បានកៀរគរភាគីពាក់ព័ន្ធមកពីគ្រប់មជ្ឈដ្ឋាន រួមមានមន្ត្រីរដ្ឋាភិបាល អ្នកអប់រំ អង្គការក្រៅរដ្ឋាភិបាលជាតិ អន្តរជាតិ អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍ ដើម្បីពិភាក្សាគ្នា ក្នុងស្មារតីស្វែងរកដំណោះស្រាយបញ្ហាប្រឈមនានា និងកាលានុវត្តភាពសំខាន់ៗក្នុងវិស័យអប់រំរបស់កម្ពុជា។ វេទិកាពិភាក្សាសំខាន់នៅក្នុងសន្និសីទជាតិលើកទី ៤ នេះរួមមានការពិភាក្សាលើការកែលម្អការអនុវត្តការអប់រំពហុភាសានៅក្នុងខេត្តរតនគិរី ការលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យអប់រំ ការបញ្ជ្រាបបរិយាបន្នសម្រាប់សិស្សមានពិការភាព និងសុខភាពសិក្សាក្នុងវិស័យអប់រំនៅថ្នាក់ខេត្ត ការលើកកម្ពស់ការបណ្តុះបណ្តាល និងការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន និងយុទ្ធសាស្ត្រសម្រាប់ហិរញ្ញប្បទានអប់រំជាដើម។ សន្និសីទនេះមានសក្តានុពលក្នុងការជំរុញឱ្យមានកិច្ចខិតខំប្រឹងប្រែងកែលម្អការអប់រំនៅកម្ពុជា តាមរយៈកិច្ចពិភាក្សារបស់វាគ្មិន ដែលមានជំនាញ និងការប្តេជ្ញាចិត្តរួមរបស់អ្នកចូលរួម។ លទ្ធផលនៃសន្និសីទសក្ខីកម្ម ជូនដំណឹងអំពីអនុវត្តគោលនយោបាយ កម្មវិធី និងគំនិតផ្តួចផ្តើមនានា ដើម្បីដោះស្រាយឧបសគ្គជាប្រព័ន្ធដែលរារាំងដល់លទ្ធភាពទទួលបានការអប់រំប្រកបដោយគុណភាព និងបរិយាបន្នសម្រាប់អ្នកសិក្សាទាំងអស់នៅកម្ពុជា។

របាយការណ៍នេះ មានគោលបំណងសង្ខេបកិច្ចពិភាក្សាសំខាន់ៗ ចំណេះដឹងនានា និងអនុសាសន៍ដែលបានចែករំលែកក្នុងអំឡុងពេលសន្និសីទរយៈពេល២ថ្ងៃពេញ។ យើងសង្ឃឹមថារបាយការណ៍នេះ នឹងរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងរួមគ្នាដើម្បីលើកកម្ពស់ការអប់រំប្រកបដោយបរិយាប័ន្ន និងសមធម៌នៅក្នុងប្រទេសកម្ពុជា តាមរយៈការសំយោគនូវចំណេះដឹង និងជំនាញជាច្រើនដែលបានចែករំលែក ទៅអនុវត្តនិងកែលម្អ។

## ២. គោលបំណងសន្និសីទ

- ជាវេទិកាសម្រាប់អ្នកពាក់ព័ន្ធ ដើម្បីពិភាក្សាអំពីបញ្ហាប្រឈមដែលកំពុងកើតមាននៅក្នុងវិស័យអប់រំ
- ជំរុញការយល់ដឹងរួមអំពីបញ្ហាប្រឈមទាក់ទងនិងគម្លាតនៃការអនុវត្តគោលនយោបាយ
- ការបំផុសគំនិត និងការស្វែងរកដំណោះស្រាយសមស្របឆ្លើយតបទៅនឹងបញ្ហាប្រឈម

- ផ្តល់ជាអនុសាសន៍ទៅលើបញ្ហាប្រឈម

## ៣. មតិស្វាគមន៍

### ៣.១ សុន្ទរកថាស្វាគមន៍របស់លោកស្រី ម៉ាក ចាន់ស៊ីថា ក្រុមប្រឹក្សាភិបាលនៃ អង្គការភាពជាដៃគូអប់រំ នៃអង្គការក្រៅរដ្ឋាភិបាល

លោកស្រីម៉ាក ចាន់ស៊ីថា បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួងអប់រំ យុវជន និងកីឡា សម្រាប់កិច្ចខិតខំប្រឹងប្រែងគួរឱ្យកត់សម្គាល់ក្នុងការកែលម្អប្រព័ន្ធអប់រំនៅកម្ពុជា។ លោកស្រីបានលើកឡើងពីបញ្ហាប្រឈមសំខាន់ៗនៅក្នុងវិស័យអប់រំ រួមទាំងការទទួលបានការអប់រំសម្រាប់សិស្សមានពិការភាព គម្លាតនៃការអប់រំនៅជនបទ និងតំបន់ដាច់ស្រយាល អត្រាបោះបង់ការសិក្សាខ្ពស់ និងឧបសគ្គលើការអនុវត្តការអប់រំពហុភាសា។

### ៣.២ សុន្ទរកថារបស់លោក Thomas White នាយកការិយាល័យប្រជាធិបតេយ្យ និងអភិបាលកិច្ច នៃទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ ប្រចាំប្រទេសកម្ពុជា (USAID)

តំណាងទីភ្នាក់ងារជំនួយអាមេរិក USAID បានស្វាគមន៍យ៉ាងកក់ក្តៅចំពោះអ្នកចូលរួម និងបានសង្កត់ធ្ងន់លើសារៈសំខាន់នៃសន្និសីទនេះ ជាវេទិកាមួយសម្រាប់ភាគីពាក់ព័ន្ធក្នុងការជួបជុំ ពិភាក្សាអំពីទិដ្ឋភាពនៃការអប់រំនៅកម្ពុជា ដោយផ្តោតជាសំខាន់លើការពង្រឹងភាពជាដៃគូរវាងអង្គការក្រៅរដ្ឋាភិបាល និងរដ្ឋាភិបាល ដើម្បីពង្រឹងប្រព័ន្ធអប់រំ។ ដោយឆ្លុះបញ្ចាំងពីអនុសាសន៍សំខាន់របស់សន្និសីទជាតិលើកទី ៣ កាលពីឆ្នាំមុន លោកបានលើកឡើងថាការលើកកម្ពស់គោលនយោបាយអប់រំបរិយាបន្ន និងការវិនិយោគនៅក្នុងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនពិតជាមានសារៈសំខាន់ក្នុងការគាំទ្រដល់ការសិក្សារបស់សិស្សប្រកបដោយប្រសិទ្ធភាព។ លោកបន្តទៀតថា កិច្ចខិតខំប្រឹងប្រែងរបស់ទីភ្នាក់ងារជំនួយអាមេរិក USAID គឺផ្តោតលើការកសាងសមត្ថភាព និងគណនេយ្យភាពរបស់ក្រសួងអប់រំ យុវជន និងកីឡា ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយផ្តោតលើ លើជំនាញរបស់គ្រូ និងនាយកសាលាបច្ចេកទេសអប់រំបរិយាន្ន ដើម្បីរួមបញ្ចូលការគាំទ្រជាច្រើនដល់ស្ថាប័នសិស្ស និងគ្រូ ការពង្រឹងប្រព័ន្ធ និងការប្រើប្រាស់វិន័យវិជ្ជមានដើម្បីលើកកម្ពស់ការសិក្សារបស់សិស្ស និងកាត់បន្ថយអំពើហិង្សានៅក្នុងសាលារៀន។ លោកបានរំលឹកឡើងវិញនូវការប្តេជ្ញាចិត្តក្នុងការជំរុញកំណែទម្រង់អប់រំ និងការសម្រេចបាននូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាពទី៤ (SDG4) នៅឆ្នាំ២០៣០ ដោយទទួលស្គាល់ការរួមចំណែកដ៏មានតម្លៃរបស់ដៃគូអភិវឌ្ឍ និងអង្គការក្រៅរដ្ឋាភិបាលឆ្ពោះទៅរកគោលដៅរួមមួយ។ លោកបានថ្លែងអំណរគុណចំពោះក្រសួង អ.យ.ក និងអង្គការភាពជាដៃគូអប់រំ នៃអង្គការក្រៅរដ្ឋាភិបាល ដែលបានសហការ និងគាំទ្រ។ ជាទីបញ្ចប់ លោកបានជូនពរដល់អ្នកចូលរួមទាំងអស់នូវការពិភាក្សាប្រកបដោយផ្លែផ្កា និងបទពិសោធន៍ដ៏មានតម្លៃនៅក្នុងសន្និសីទនេះ។

## ៣.៣ សុន្ទរកថាបើកសន្និសីទក្រោមអធិបតីភាព ឯកឧត្តម អ៊ុង បូរាត រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា

សុន្ទរកថាបើកសន្និសីទជាតិលើកទី៤ ក្រោមអធិបតីភាព ឯកឧត្តម អ៊ុង បូរាត រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា បានគូសបញ្ជាក់អំពីតួនាទីសំខាន់នៃកិច្ចសហការរវាងក្រសួងអប់រំ យុវជន និងកីឡា និងអង្គការក្រៅរដ្ឋាភិបាល ដូចជា អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល ក្នុងការដោះស្រាយបញ្ហាប្រឈម ឬឧបសគ្គនានា ក្នុងវិស័យអប់រំ។ ឯកឧត្តមបានលើកឡើងអំពីភាពចាំបាច់នៃការសម្របខ្លួនទៅនឹងទិដ្ឋភាពនៃការវិវត្ត ន៍ក្នុងវិស័យអប់រំ ជាពិសេសចំពោះបញ្ហាដែលបណ្តាលមកពីការរាតត្បាតនៃជំងឺកូវីដ-១៩ និងការរីកចំរើននៃបច្ចេកវិទ្យាយ៉ាងឆាប់រហ័ស។ ឆ្លៀតក្នុងឱកាសនេះ ឯកឧត្តមបានលើកឡើងនូវសំណុំអាទិភាពវិស័យអប់រំទាំង ៨ ដែលបានដាក់ចេញក្នុងគោលបំណង ដោះស្រាយបញ្ហា ឬក្តីកង្វល់នាពេលបច្ចុប្បន្ននេះ ប្រកបដោយប្រសិទ្ធភាព ដើម្បីធ្វើឱ្យប្រព័ន្ធអប់រំកាន់តែមានភាពធន់ និងត្រៀមខ្លួនជាស្រេចសម្រាប់ទទួលយកនូវស្ថានភាពណាមួយនាពេលអនាគត ព្រមទាំងចូលរួមដោយស្រាយបញ្ហានៃសិក្សារៀនសូត្រ និងវិសមភាពផងដែរ។ សំណុំអាទិភាពទាំងនោះរួមមាន៖

- អាទិភាពទី១ "**ធានាឱ្យការបើកសាលារៀនឡើងវិញប្រកបដោយសុវត្ថិភាព ការស្តារ ឡើងវិញនូវការរៀនសូត្រ និងការបន្តការសិក្សា**" ទទួលបានលទ្ធផលល្អប្រសើរ។
- អាទិភាពទី២ "**កំណែទម្រង់សាលារៀន**" ដែលផ្តោតលើគណនេយ្យភាព ស្វ័យភាព ការវាយតម្លៃ និងការចូលរួម
- អាទិភាពទី៣ "**ការអភិវឌ្ឍគ្រូបង្រៀនឱ្យមានគុណភាពខ្ពស់**" តាមរយៈកំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ
- អាទិភាពទី៤ "**ការអប់រំឌីជីថល**"
- អាទិភាពទី៥ គឺ "**ការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និង គណិតវិទ្យា" ដើម្បីឆ្លើយ តបនឹងបដិវត្តឧស្សាហកម្មទី ៤.០**"
- អាទិភាពទី៦ "**ការអភិវឌ្ឍជំនាញសតវត្សទី២១សម្រាប់យុវជន**" ដែលជាជំហានមួយសម្រាប់ប្រទេសកម្ពុជាដើម្បីប្រែក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០
- អាទិភាពទី៧ "**ការបង្កើតមជ្ឈមណ្ឌលឧត្តមភាពនៅកម្រិតឧត្តមសិក្សា**" តាមរយៈការពង្រឹងអភិបាលកិច្ចរបស់គ្រឹះស្ថានឧត្តមសិក្សា ការបង្កើនគុណវុឌ្ឍរបស់សាស្ត្រាចារ្យ ការស្រាវជ្រាវនិងនវានុវត្តន៍ ការបង្កើតសាកលវិទ្យាល័យសាយប័រ និងការផ្សារភ្ជាប់ទីផ្សារការងារ។
- អាទិភាពទី៨ "**ការពង្រឹងសមត្ថភាពស្ថាប័ន និងការកសាងប្រព័ន្ធអប់រំ**" ដោយឈរលើមូលដ្ឋាននៃការប្រែក្លាយវិបត្តិជំងឺកូវីដ-១៩ ទៅជាកាលានុវត្តភាពសម្រាប់កំណែទម្រង់ និងកែលម្អប្រព័ន្ធអប់រំឱ្យមានភាពធន់ សម្រាប់ពេលអនាគត។

សុន្ទរកថារបស់ឯកឧត្តមបានបញ្ចប់ដោយការសម្តែងការអរគុណចំពោះការចូលរួម និងកិច្ចសហប្រតិបត្តិការជាសមូហភាពឆ្ពោះទៅរកការកែលម្អលទ្ធផលអប់រំសម្រាប់កុមារ និងយុវជនកម្ពុជា។

## ៤. វេទិកាពិភាក្សា

### ៤.១ វេទិកាពិភាក្សាស្តីពី ការវិភាគការអនុវត្តគោលនយោបាយបរិយាបន្ន និងគោលនយោបាយសុខភាពសិក្សានៅខេត្តកំពត

វេទិកាពិភាក្សាស្តីពីការវិភាគការអនុវត្តគោលនយោបាយនៅខេត្តកំពតបានសង្កត់ធ្ងន់លើការបញ្ជ្រាបបរិយាបន្នសម្រាប់សិស្សមានពិការភាព និងការលើកកម្ពស់សុខភាពសិក្សា។ បញ្ហាដែលបានលើកឡើងរួមមាន កង្វះឧបករណ៍សង្គ្រោះបឋមសម្រាប់សិស្សានុសិស្សនៅតាមសាលារៀន (រួមទាំងសម្ភារៈអនាម័យសម្រាប់ក្មេងស្រី) អាហារមិនមានសុវត្ថិភាពនៅតាមគ្រឹះស្ថានសិក្សា ការយល់ដឹងរបស់សហគមន៍ទៅលើសុវត្ថិភាពអាហារនៅមានកម្រិត និងហេដ្ឋារចនាសម្ព័ន្ធសាលាមិនទាន់មានបរិយាបន្នសម្រាប់សិស្សមានពិការភាព។ អនុសាសន៍ដែលបានលើកឡើងដើម្បីឆ្លើយតបនឹងបញ្ហាទាំងអស់នេះផ្តោតលើការបណ្តុះបណ្តាលគ្រូ យន្តការត្រួតពិនិត្យតាមដាន និងការបង្កើនការបែងចែកថវិកាសម្រាប់ការអប់រំបរិយាបន្ន។

#### ៤.១.១ ការបញ្ជ្រាបបរិយាបន្នសម្រាប់សិស្សមានពិការភាព និងសុខភាពសិក្សាក្នុងវិស័យអប់រំនៅថ្នាក់ខេត្ត ដោយលោក វ៉េត ស៊ីណាន ប្រធានគម្រោងនៅអង្គការគម្រោងពុទ្ធិកបណ្ណាល័យកម្ពុជា និងជាប្រធានក្រុមការងារគាំទ្រវិស័យអប់រំខេត្តកំពត(Kampot ESWG) និងលោកស្រី អន សុខនី នាយកប្រចាំប្រទេសនៃអង្គការអេពិកអាត (Epic Arts)

ក្រុមការងារគាំទ្រវិស័យអប់រំខេត្តកំពតកំពុងតែធ្វើការស្វែងរកមតិគាំទ្រដ៏ស្វិតស្វាញដើម្បីការពង្រឹងអប់រំបរិយាបន្ន និងសុខភាពសិក្សានៅក្នុងខេត្តកំពត។ បេសកកម្មរបស់ពួកគេផ្តោតលើការធានាថាសិស្សទាំងអស់ រួមទាំងជនមានពិការភាព មានសិទ្ធិទទួលបានការអប់រំប្រកបដោយគុណភាព សមធម៌ និងសុខភាព។

ពួកគេបានពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធផ្សេងៗនៅថ្នាក់ខេត្ត ដើម្បីកំណត់បញ្ហាដែលមិនទាន់បានដោះស្រាយពាកព័ន្ធនឹងសុខភាពសិក្សា ដែលវាជាកត្តាមួយធ្វើឱ្យមានផលប៉ះពាល់ដល់ការលូតលាស់ និងសុខភាពរបស់សិស្ស។ បញ្ហាទាំងនោះសង្កត់ធ្ងន់លើការផ្តល់ឧបករណ៍ជំនួយចាំបាច់មិនទាន់មានភាពគ្រប់គ្រាន់សម្រាប់ក្មេងស្រី ការលក់អាហារគ្មានសុវត្ថិភាពនៅក្នុងបរិវេណសាលា និងការយល់ដឹងរបស់សហគមន៍អំពីសុវត្ថិភាពចំណីអាហារនៅមានកម្រិត។

លោក វ៉េត ស៊ីណាន បានផ្តល់អនុសាសន៍ដ៏មានខ្លឹមសារដូចជា៖

- បណ្តុះបណ្តាលគ្រូបង្រៀននៅតាមសាលាគោលដៅស្តីពីអាហារូបត្ថម្ភ ពង្រឹងបន្ថែមលើការងារ ទឹកស្អាត អនាម័យ និងបរិស្ថានជាពិសេសអនាម័យរបស់ក្មេងស្រី
- ពង្រឹងការត្រួតពិនិត្យ និងវាយតម្លៃលើការងារសុវត្ថិភាពចំណីអាហារ និងបរិស្ថានសាលាអោយបានទៀងទាត់
- បង្កើនការវិភាជន៍ថវិកាជាតិសម្រាប់ការអនុវត្តសុខភាពសិក្សា

– ពង្រឹងការចូលរួមរបស់សហគមន៍លើការអនុវត្តគោលនយោបាយសុខភាពសិក្សាតាមសាលារៀន
– អំពាវនាវឱ្យមានកិច្ចខិតខំប្រឹងប្រែងរួមគ្នាដើម្បីពង្រឹងការអនុវត្តអនាម័យ ពង្រឹងយន្តការត្រួតពិនិត្យ បង្កើនការបែងចែកថវិកាសម្រាប់ការអប់រំសុខភាព និងការចូលរួមសហគមន៍ក្នុងការអនុវត្តគោលនយោបាយ
– ផ្តល់កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនបន្ថែមនូវជំនាញចាំបាច់ដើម្បីបំពេញតម្រូវការសិស្សមានពិការ អភិវឌ្ឍសម្ភារៈសិក្សា សម្រាប់សិស្សានុសិស្សដែលមានតម្រូវការពិសេស

រីឯអង្គការអេពិកអាត (Epic Arts) ដែលជាអង្គការក្រៅរដ្ឋាភិបាលសកម្មមួយក្នុងខេត្តកំពត និងជាសមាជិកនៃ ESWG របស់ខេត្តកំពត បានចែករំលែកអំពីគម្រោងរបស់ខ្លួនដែលបានចូលរួមដោះស្រាយគម្លាតនៃការអប់រំបរិយាបន្នរបស់ខ្លួនតាមរយៈការលើកកម្ពស់ការអប់រំពិសេស។ គម្រោងទាំងនោះរួមមានការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការបណ្តុះបណ្តាលគ្រូបង្រៀន និងការគាំទ្រដល់កុមារពិការនិងគ្រួសាររបស់ពួកគេ។ លោកស្រីបន្តលើកឡើងពីបញ្ហាប្រឈមដូចជាកង្វះធនធាន កង្វះការបង្កើនថវិកា ប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយ និងការសហការជាមួយអង្គការក្រៅរដ្ឋាភិបាល។

## ៤.១.២ ការបញ្ជ្រាបបរិយាបន្នក្នុងវិស័យអប់រំនៅថ្នាក់ជាតិ ដោយលោក ទឹម សាហែន អនុប្រធាននាយកដ្ឋានអប់រំពិសេស នៃក្រសួងអប់រំយុវជន និងកីឡា ។

នាយកដ្ឋានអប់រំពិសេសបានបង្ហាញសមិទ្ធិផលក្នុងការអប់រំបរិយាបន្ន និងការកសាងសមត្ថភាពគ្រូបង្រៀន។ សមិទ្ធផលសំខាន់ៗមានដូចជាការផ្តល់អប់រំដល់កុមារពិការភ្នែក ការដាក់បញ្ចូលជំនាញសម្រាប់គ្រូបង្រៀននៅក្នុងថ្នាក់បរិយាបន្ន និងវិទ្យាល័យអប់រំពិសេស ការផលិតវីដេអូរៀនភាសាសញ្ញា ការគាំទ្រអាហារ ការស្នាក់នៅ ការចំណាយលើការធ្វើដំណើរ ដល់សិស្សពិការភ្នែក គថ្លង់ អូទីស្សឹម ។

នាយកដ្ឋានគ្រោងនឹងបង្កើត និងផ្សព្វផ្សាយផែនការសកម្មភាពស្តីពីការអប់រំបរិយាបន្ន បង្កើតកម្មវិធីសិក្សាលម្អិត និងការផ្គត់ផ្គង់សាលារៀនសម្រាប់ការអប់រំពិសេស ដើម្បីឆ្លើយតបទៅនឹងបដិវត្តន៍ឌីជីថល លើកកម្ពស់សមត្ថភាពគ្រូបង្រៀនក្នុងការអប់រំបរិយាបន្ន និងរៀបចំសម្ភារៈសិក្សាសម្រាប់សិស្សគថ្លង់។ វិធីសាស្ត្រដ៏ទូលំទូលាយនេះមានគោលបំណងដោះស្រាយតម្រូវការចម្រុះរបស់សិស្សពិការ និងលើកកម្ពស់ការអនុវត្តការអប់រំរួមបញ្ចូលទូទាំងប្រទេស។ លោកទឹមសាហែនបានសង្កត់ធ្ងន់លើសារៈសំខាន់នៃការគាំទ្រ កិច្ចសហប្រតិបត្តិការ ពីភាគីពាក់ព័ន្ធទៅលើផែនការសកម្មភាពអប់រំបរិយាបន្ន និងការបង្កើតកម្មវិធីសិក្សា និងសម្ភារៈសម្រាប់ការអប់រំពិសេស។ លោកបានញ្ជាក់បន្ថែមពីតម្រូវការក្នុងការអន្តរាគមន៍ពីភាគីពាក់ព័ន្ធ ដើម្បីដោះស្រាយគម្លាតជាក់លាក់របស់សិស្សដែលមានពិការភាព និងធានាឱ្យមានការចូលរួមពេញលេញរបស់ពួកគេនៅក្នុងឱកាសសិក្សា។ កិច្ចអន្តរាគមន៍ទាំងនេះរួមមានការកសាងសមត្ថភាពសម្រាប់គ្រូអប់រំមត្តេយ្យសិក្សា ផែនការបង្រៀនមួយទល់មួយជាមួយកុមារដែលមានតម្រូវការពិសេស និងការអនុវត្តគំរូល្បែងបរិយាបន្នមត្តេយ្យសិក្សា។ នាយកដ្ឋានក៏ជួបប្រទះនូវបញ្ហាប្រឈមដូចជាកង្វះធនធាន ខ្វះគ្រូបង្រៀនតាមកម្រិតថ្នាក់ និងមុខវិជ្ជា និងគ្រូសម្របសម្រួលថ្នាក់អប់រំបរិយាបន្ន សមត្ថភាពគ្រូបង្រៀននៅវិទ្យាល័យ

អប់រំពិសេស ថ្នាក់សមាហរកម្ម ថ្នាក់អប់រំបរិយាបន្ន នៅមានកម្រិត សមត្ថភាពមន្ត្រីថ្នាក់កណ្តាល ថ្នាក់រាជធានី ខេត្ត ថ្នាក់ក្រុង ស្រុក ខណ្ឌ នៅមានកម្រិត។

## ៤.២ វេទិកាពិភាក្សាស្តីពី៖ ការវិភាគការអនុវត្តគោលនយោបាយពហុភាសានៅខេត្តរតនគិរី

វេទិកាពិភាក្សាស្តីពី ការវិភាគការអនុវត្តគោលនយោបាយនៅខេត្តរតនគិរី ផ្តោតលើការកែលម្អការអនុវត្តការអប់រំពហុភាសា ដើម្បីធានាបាននូវសមភាពទទួលបានការអប់រំប្រកបដោយគុណភាពសម្រាប់សិស្សជនជាតិភាគតិច។ ក្រុមគាំទ្រការងារវិស័យអប់រំខេត្តរតនគិរី (Ratanakiri ESWG) បានលើកឡើងពីបញ្ហាដែលកំពុងកើតមាន និងបានលើកជាអនុសាសន៍ ដោយសង្កត់ធ្ងន់លើការលើកកម្ពស់គុណភាព ការពង្រឹងសមត្ថភាពគ្រូបង្រៀន និងការពង្រីកវិសាលភាពកម្មវិធីនេះ។ លើសពីនេះ នាយកដ្ឋានអប់រំពិសេស នៃក្រសួងអប់រំ យុវជន និងកីឡាបានចែករំលែកអំពីសមិទ្ធិផល និងបញ្ហាប្រឈមក្នុងការអនុវត្តគោលនយោបាយនេះ ដោយសង្កត់ធ្ងន់លើតម្រូវការធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាដែលបានធ្វើបច្ចុប្បន្នភាព ការពង្រឹងការបណ្តុះបណ្តាលគ្រូ និងការពង្រឹងសមត្ថភាពស្ថាប័ន។

### ៤.២.១ ការកែលម្អការអនុវត្តការអប់រំពហុភាសានៅក្នុងខេត្តរតនគិរី តាមរយៈការកសាងសមត្ថភាពគ្រូបង្រៀន ការអភិវឌ្ឍសម្ភារៈបង្រៀន និងរៀន និងការលើកកម្ពស់ការយល់ដឹង និងការចូលរួមរបស់សហគមន៍ ដោយលោក ពេជ្រ យ៉េក នាយកកម្មវិធី អង្គការសហការគ្រប់ជ្រុងជ្រោយដើម្បីកម្ពុជា (ICC) និងជាប្រធានក្រុមការងារគាំទ្រវិស័យអប់រំខេត្តរតនគិរី (Ratanakiri ESWG)

ក្រុមការងារគាំទ្រវិស័យអប់រំខេត្តរតនគិរី បានធ្វើការតាមដានយ៉ាងសកម្មនូវការអនុវត្តគោលនយោបាយ អប់រំពហុភាសា និងផែនការសកម្មភាព ក្នុងខេត្តរតនគិរី ក្នុងគោលបំណងធានាថាសិស្សជនជាតិភាគតិចមានលទ្ធិភាពទទួលបានការអប់រំប្រកបដោយគុណភាព។ តាមរយៈការខិតខំប្រឹងប្រែងនេះ ពួកគេបានដោះស្រាយគម្លាតផ្នែកភាសា និងការអប់រំ ដោយជំរុញបរិយាកាសសិក្សាបរិយាបន្នសម្រាប់សិស្សទាំងអស់។

លោក ពេជ យ៉េក បានបង្ហាញពីបញ្ហាដែលកំពុងកើតមានទាក់ទងនឹង កង្វះគ្រូបង្រៀនមានជំនាញ កង្វះសម្ភារៈរៀន-បង្រៀន និងកង្វះការរួមរួមរបស់សហគមន៍ទៅលើការអនុវត្តគោលនយោបាយនេះ។ លោកបានលើកឡើងនូវអនុសាសន៍សំខាន់ដូចជា៖

- ការពង្រឹងសមត្ថភាពគ្រូបង្រៀននិងលើកកម្ពស់គុណភាពនៃកម្មវិធីនៅកម្រិតមត្តេយ្យសិក្សានិងបឋមសិក្សា
- បង្កើនធនធាន និងអភិវឌ្ឍឧបករណ៍រៀន-បង្រៀន បន្ថែមទៀតជាភាសាជនជាតិដើមភាគតិច
- ពង្រីកវិសាលភាពភាសា និងការពង្រឹងវិធីសាស្ត្របង្រៀន
- លើកកម្ពស់ការចូលរួមសហគមន៍នៅក្នុងដំណើរការលើកកម្ពស់ការអប់រំពហុភាសា។

លោកសង្ឃឹមថា អង្គការក្រៅរដ្ឋាភិបាល និងនាយកដ្ឋានទទួលបន្ទុក នៃក្រសួងអប់រំ យុវជន និងកីឡា និងស្វែងរកកិច្ចខិតខំប្រឹងប្រែងរួមគ្នាដើម្បីដោះស្រាយនូវបញ្ហាទាំងអស់នោះ។

### ៤.២.២ ការលើកកម្ពស់អប់រំពហុភាសាក្នុងចំណោមក្រុមជនជាតិដើមភាគតិច ជាអាទិភាពរបស់ក្រសួងអប់រំ យុវជន និងកីឡា ដោយលោកស្រី ជិន កល្យាណលក្ខិណា អនុប្រធាននាយកដ្ឋានអប់រំពិសេស

នាយកដ្ឋានអប់រំពិសេសនៃក្រសួងអប់រំ យុវជន និងកីឡា បានបង្ហាញពីវឌ្ឍនភាពក្នុងការអនុវត្តការអប់រំពហុភាសា ដោយគូសបញ្ជាក់ពីសមិទ្ធិផល និងបញ្ហាប្រឈមសំខាន់ៗមួយចំនួន។ សមិទ្ធផលគួរឱ្យកត់សម្គាល់រួមមានការអនុវត្តកម្មវិធីអប់រំពហុភាសាដោយជោគជ័យសម្រាប់កុមារជនជាតិដើមភាគតិចនៅទូទាំងខេត្ត នៅកម្រិតថ្នាក់មត្តេយ្យសិក្សា និងបឋមសិក្សា។ កិច្ចខិតខំប្រឹងប្រែងផ្សេងទៀតរួមមានការផលិត និងផ្សព្វផ្សាយធនធានអប់រំឌីជីថលជាភាសាជនជាតិដើមភាគតិច ការធ្វើសិក្ខាសាលាដើម្បីកែលម្អសៀវភៅសិក្សា និងកម្មវិធីសិក្សា និងផ្តល់ការបណ្តុះបណ្តាលដល់គ្រូបង្រៀននៅកម្រិតផ្សេងៗ។ បញ្ហាប្រឈមរួមមានកម្មវិធីសិក្សាហួសសម័យ សម្ភារៈបង្រៀនមិនគ្រប់គ្រាន់ សមត្ថភាពមានកម្រិតក្នុងចំណោមគ្រូបង្រៀនពហុភាសា និងសមត្ថភាពស្ថាប័ន នៅកម្រិត រដ្ឋបាលផ្សេងៗនៅថ្នាក់កណ្តាល។ លោកស្រីបានសង្កត់ធ្ងន់លើតម្រូវការសម្រាប់ការបន្តគាំទ្រ និងការកសាង សមត្ថភាពដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ ដោយអំពាវនាវឱ្យមានសកម្មភាពរួមមានជាមួយក្រសួងក្នុងការធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សា សម្ភារៈសិក្សា ការលើកកម្ពស់ការបណ្តុះបណ្តាលគ្រូបង្រៀន និងការពង្រឹងសមត្ថភាពស្ថាប័ននៅគ្រប់កម្រិត ដើម្បីជំរុញវឌ្ឍនភាពនៃការអនុវត្តអប់រំពហុភាសាឱ្យកាន់តែប្រសើរបន្ថែមទៀត។

### ៤.២.៣ សំនួរ-ចម្លើយ

អ្នកចូលរួមបានលើកឡើងនូវសំណួរទាក់ទងនឹងមធ្យោបាយងាយស្រួលក្នុងការទទួលបានសៀវភៅនៅតំបន់ដាច់ស្រយាល។ វាគ្មិនបានឆ្លើយតបដោយគូសបញ្ជាក់ពីកិច្ចខិតខំប្រឹងប្រែងសហការដែលពាក់ព័ន្ធនឹងក្រសួង និងអង្គការក្នុងស្រុកដូចជាអង្គការសហការណ៍គ្រប់គ្រង់ជ្រោយដើម្បីកម្ពុជា ដើម្បីបង្កើនលទ្ធភាពទទួលបានសៀវភៅ បណ្តុះបណ្តាលគ្រូបន្ថែមដែលមានជំនាញចាំបាច់ដើម្បីបង្រៀនដោយពិគ្រោះយោបល់ជាមួយសាលា។ លើសពីនេះ ការចូលរួមរបស់សហគមន៍មូលដ្ឋានក៏ជាកត្តាសំខាន់ក្នុងការធានាការអនុវត្តការអប់រំពហុភាសាប្រកបដោយជោគជ័យផងដែរ។

## ៤.៣ វេទិកាពិភាក្សាស្តីពី៖ ការវិភាគការអនុវត្តគោលនយោបាយនៅខេត្តសៀមរាប

វេទិកាពិភាក្សាស្តីពី ការវិភាគការអនុវត្តគោលនយោបាយនៅខេត្តសៀមរាបគឺផ្តោតលើការលើកកម្ពស់សមភាព យេនឌ័រក្នុងវិស័យអប់រំ ដើម្បីបង្កើនលទ្ធផលសិក្សារបស់សិស្ស។ ក្រុមការងារគាំទ្រវិស័យអប់រំខេត្តសៀមរាប (SEST) បានសង្កត់ធ្ងន់លើសារៈសំខាន់នៃការលើកកម្ពស់ការយល់ដឹង ការបណ្តុះបណ្តាលគ្រូ និងការបែងចែកថវិកាសម្រាប់គំនិតផ្តួចផ្តើមដែលឆ្លើយតបនឹងយេនឌ័រ។ បញ្ហាដែលបានលើកឡើងមានដូចជា គ្រូជាប់កិច្ចសន្យាមិនមានប្រាក់

ឧបត្ថម្ភ ច្បាប់សម្រាកលម្ហែមាតុភាព និងកង្វះការបណ្តុះបណ្តាលយេនឌ័រ។ ក្រសួងអប់រំ យុវជន និងកីឡាបានគូស បញ្ជាក់ពីកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេក្នុងការបញ្ចូលទស្សនៈយេនឌ័រទៅក្នុងការអនុវត្តវិស័យអប់រំតាម រយៈ គោលនយោបាយ ផែនការយុទ្ធសាស្រ្តជាច្រើន ប៉ុន្តែទោះជាយ៉ាងណាក្តីក៏នៅតែមានបញ្ហាប្រឈមទាក់ទងនិងការប ណ្តុះ បណ្តាលចំណេះដឹងអំពីយេនឌ័រ និងកម្រិតថវិកា។

## ៤.៣.១ ការកែលម្អលទ្ធផលនៃការសិក្សារបស់សិស្សតាមរយៈការលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យអប់រំ ដោយលោកស្រី កែវ ណាវ៉ាត់ តំណាងក្រុមគាំទ្រការងារវិស័យអប់រំខេត្តសៀមរាប (SEST) និងជាអ្នកសម្រប សម្រួលកម្មវិធីនៅអង្គការជីវិតនៅកម្ពុជា

ក្រុមគាំទ្រការងារវិស័យអប់រំខេត្តសៀមរាប (SEST) កំពុងធ្វើការងាររបស់ខ្លួនដោយផ្តោតលើការលើកកម្ពស់ សមភាពយេនឌ័រក្នុងវិស័យអប់រំ ដោយដោះស្រាយបញ្ហាប្រឈមទាក់ទងនឹងយេនឌ័រ ដែលជាមូលហេតុមួយក្នុងការ រារាំងដល់លទ្ធផលសិក្សារបស់សិស្ស។ លោកស្រីតំណាង SEST បានបង្ហាញនូវការរកឃើញសំខាន់របស់ក្រុមខ្លួន ដូចជា៖

- កង្វះប្រាក់ឧបត្ថម្ភ និងការឈប់សម្រាកលំហែមាតុភាពសម្រាប់គ្រូបង្រៀនជាប់កិច្ចសន្យា
- ការបណ្តុះបណ្តាលយេនឌ័រមិនគ្រប់គ្រាន់សម្រាប់អ្នកគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន
- ភាពខុសគ្នារវាងយេនឌ័រក្នុងការចុះឈ្មោះសិស្ស។

ដើម្បីឆ្លើយតបទៅនឹងការរកឃើញទាំងនេះ និងលើកកម្ពស់ការយល់ដឹងអំពីយេនឌ័រ សមភាពក្នុងវិស័យអប់រំ លោកស្រីបានលើកឡើងនូវអនុសាសន៍ក៏មានខ្លឹមសារមួយចំនួនដូចជា៖

- គាំទ្រប្រាក់ឧបត្ថម្ភមាតុភាព និងការឈប់សម្រាកសម្រាប់គ្រូបង្រៀនជាប់កិច្ចសន្យា
- ផ្តល់ការបណ្តុះបណ្តាលគរុកោសល្យដែលឆ្លើយតបនឹងយេនឌ័រ
- បង្កើត និងផ្សព្វផ្សាយគោលនយោបាយដើម្បីលើកកម្ពស់សមភាពយេនឌ័រនៅក្នុងសាលារៀន
- និងពង្រឹងយន្តការសម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយេនឌ័រ។

លោកស្រីបានបញ្ជាក់ផងដែរថា តាមរយៈការអនុវត្តសកម្មភាពទាំងនេះ យើងអាចជំរុញប្រព័ន្ធអប់រំបរិយា បន្នកាន់តែច្រើន ដែលផ្តល់សិទ្ធិអំណាចដល់សិស្សទាំងអស់ ដោយមិនគិតពីនិន្នាការភេទ។

### ៤.៣.២ ការអនុវត្តការរៀន និងបង្រៀនដែលឆ្លើយតបនឹងយេនឌ័រក្នុងផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន ដើម្បីគុណភាពបង្រៀនកាន់តែប្រសើរឡើង ដោយលោកស្រី ផន សុភា នាយកដ្ឋានបណ្តុះបណ្តាលនៃក្រសួងអប់រំ យុវជន និងកីឡា

ក្រសួងអប់រំ យុវជន និងកីឡា បានបង្ហាញការប្តេជ្ញាចិត្តក្នុងការដោះស្រាយអំពីតម្រូវការយេនឌ័រក្នុងការរៀន និងបង្រៀន និងខិតខំប្រឹងប្រែងជាបន្តបន្ទាប់ក្នុងការបញ្ចូលទស្សនៈយេនឌ័រទៅក្នុងការអនុវត្តអប់រំតាមរយៈ គោលនយោបាយ និងឯកសារយុទ្ធសាស្ត្រផ្សេងៗ រួមទាំង៖

- ផែនការយុទ្ធសាស្ត្រសម្រាប់បញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំ ឆ្នាំ២០២១-២០២៥
- ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៩-២០២៣
- ផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០២៤-២០៣០
- កម្មវិធី បណ្តុះបណ្តាលគ្រូបងៀន កម្រិតបឋមសិក្សា១២+២ តាមប្រព័ន្ធក្រេឌីត
- ឯកសារវគ្គបំប៉នស្តីពីភាពឆាប់ចាប់អារម្មណ៍លើយេនឌ័រក្នុងការអប់រំ
- ឯកសារបំប៉នគ្រូបង្រៀនកម្រិតមូលដ្ឋានយេនឌ័រឆ្នាំ ២០០៩
- ឯកសារបំប៉នស្តីពីចំណេះដឹងយេនឌ័រ និងស្ត្រីក្នុងភាពជាអ្នកដឹកនាំគ្រប់គ្រង ឆ្នាំ២០១៤
- ឯកសារប្រឹក្សាសាលារៀន
- ការវាយតម្លៃ របាយការណ៍វាយតម្លៃយេនឌ័រក្នុងការអប់រំគ្រូបង្រៀននៅកម្ពុជា
- ឯកសារបណ្តុះបណ្តាលស្តីពីការបញ្ជ្រាបរេនឌ័រនៅក្នុងការអប់រំគ្រូបង្រៀន។

ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងយ៉ាងណាក្តី ក៏បញ្ហាប្រឈមនៅតែបន្តកើតមាន ដូចជាគ្រូបណ្តុះបណ្តាលខ្វះការបណ្តុះបណ្តាលចំណេះដឹងផ្នែកយេនឌ័រ ថវិកាមិនគ្រប់គ្រាន់សម្រាប់អនុវត្តសកម្មភាពនានា។ គោលដៅបន្តរបស់ក្រសួងគឺបន្តលើកកម្ពស់ការអនុវត្តយេនឌ័រនៅក្នុងស្ថាប័ន ដោយសង្កត់ធ្ងន់លើការអប់រំគ្រូបង្រៀនដែលកំពុងបន្ត និងការអនុវត្តសកម្មភាពដែលបានគ្រោងទុក ដើម្បីលើកកម្ពស់សមភាពយេនឌ័រដើម្បីឆ្លើយតបទៅនឹងការរៀន និងការបង្រៀនដែលឆ្លើយតបនិងតម្រូវការយេនឌ័រ។

## ៤.៤ វេទិកាពិភាក្សា៖ យុទ្ធសាស្ត្រសម្រាប់ការធ្វើវិនិច្ឆ័យអប់រំ ការទប់ស្កាត់អត្រាបោះបង់ការសិក្សា និងការតម្រង់អាជីព

វេទិកាពិភាក្សាវគ្គនេះ មានគោលបំណងស្វែងយល់អំពីឫសគល់នៃអត្រាបោះបង់ការសិក្សា និងស្វែងរកដំណោះស្រាយផ្នែកគោលនយោបាយដែលមានសក្តានុពលដោយប្រើឧបករណ៍វិនិច្ឆ័យ។ លើសពីនេះវគ្គនេះក៏បានបង្ហាញឱ្យឃើញពីសារៈសំខាន់នៃការដោះស្រាយកត្តាសេដ្ឋកិច្ចសង្គម ការផ្តល់ការណែនាំអំពីអាជីពដ៏ទូលំទូលាយ និងការអនុវត្តអន្តរាគមន៍គោលដៅដើម្បីកាត់បន្ថយអត្រាបោះបង់ការសិក្សា និងកែលម្អលទ្ធផលអប់រំសម្រាប់សិស្សទាំងអស់។

## ៤.៤.១ ឧបករណ៍វិនិច្ឆ័យសម្រាប់ការកែលម្អគោលនយោបាយ ៖ ករណីសិក្សាស្តីពីការបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិនៅកម្ពុជា ដោយលោកស្រី សៀន លីនដា នាយកដ្ឋានគោលនយោបាយនៃក្រសួងអប់រំ

អត្រាបញ្ចប់ការសិក្សា មធ្យមសិក្សាបឋមភូមិ នៅកម្ពុជាបានកើនឡើងបន្តិចប៉ុណ្ណោះចាប់តាំងពីការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៩ (ESP)។ ទន្ទឹមនេះដែរ អត្រាបោះបង់ការសិក្សាបានកើនឡើង ដោយឈានដល់ ១៨.៦% ដែលចំនួន ៣.២% ភាគរយនៅពីលើបន្ទាត់មូលដ្ឋាន។ ការសិក្សានេះផ្តោតទៅលើការវិភាគបញ្ហានៃការបោះបង់ការសិក្សានៅកម្ពុជា ដោយផ្តោតជាពិសេសទៅលើកម្រិតមធ្យមសិក្សាបឋមភូមិក្នុងក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។ ក្នុងឆ្នាំសិក្សា ២០១៩-២០២០ តំបន់នេះមានអត្រាបោះបង់ការសិក្សាខ្ពស់បំផុតនៅក្នុងប្រទេស ដែលមានចំនួន ៣៦.៣% ។ ការវិភាគបានកំណត់មូលហេតុសក្តានុពលពីរដែលបណ្តាលឱ្យមានអត្រាបោះបង់ការសិក្សាខ្ពស់គឺ ឧបសគ្គដែលទាក់ទងនឹងគ្រូ និងកត្តាដែលទាក់ទងសាលារៀនឬគ្រួសារ។ ដំណាក់កាលដំបូងនៃកិច្ចអន្តរាគមន៍គឺ ការពង្រឹងគណៈកម្មាធិការគាំទ្រសាលារៀន ដោយមានការចូលរួមពីមាតាបិតា និងសហគមន៍ក្នុងការបង្កើតប្រព័ន្ធព្រមានមួយដើម្បីការពារការបោះបង់ការសិក្សា និងការជួលបុគ្គលិកសង្គមកិច្ចឱ្យប្រឹក្សាដល់គ្រួសារ និងគ្រូបង្រៀន។ លើសពីនេះទៀត ដើម្បីឆ្លើយតបទៅនឹងឧបសគ្គទាក់ទងនឹងគ្រូបង្រៀន ក្រសួងបានដាក់ចេញឱ្យប្រើប្រាស់ ប្រព័ន្ធយុទ្ធសាស្ត្រលើកកម្ពស់លទ្ធផលការអប់រំ (SABER) ដើម្បី៖

- វិភាគទៅលើផែនការសកម្មភាព គោលនយោបាយស្តីពីគ្រូបង្រៀន
- លើកកម្ពស់ការបន្តការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (CPD)
- ដើម្បីពង្រឹងការអនុវត្តស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀននៅតាមសាលារៀន
- ពង្រឹងការបណ្តុះបណ្តាលគ្រូ (PRESET)
- និងការធ្វើឱ្យប្រសើរឡើងនូវគុណវុឌ្ឍិសិក្សា និងជំនាញគរុកោសល្យ។

បញ្ហាផ្នែកសង្គមសេដ្ឋកិច្ច ត្រូវបានស្នើឱ្យផ្តល់អាហារូបករណ៍ដល់កុមារ និងភ្ជាប់ឪពុកម្តាយជាមួយនឹងជំនួយសង្គមតាមរយៈការផ្ទេរសាច់ប្រាក់។

## ៤.៤.២ ទប់ស្កាត់ការបោះបង់ការសិក្សាពីបឋមសិក្សាដល់មធ្យមសិក្សាទុតិយភូមិ និងមធ្យមសិក្សាទុតិយភូមិ ដោយលោក តុល សុផាត អ្នកគ្រប់គ្រងកម្មវិធីនៅអង្គការកម្ពុជាដើម្បីកុមារ និងការអភិវឌ្ឍន៍ (COCD)

គម្រោងអាហារូបករណ៍របស់អង្គការកម្ពុជាដើម្បីកុមារ និងការអភិវឌ្ឍន៍ (COCD) មានគោលបំណងជួយដល់កុមារីងាយរងគ្រោះនៅក្នុងស្រុកថាលាសែនជ័យ និងស្រុកក្រវាញ នៃខេត្តពោធិ៍សាត់ ដែលប្រឈមនឹងការបោះបង់ការសិក្សានៅចន្លោះថ្នាក់ទី ១០ ដល់ទី ១២។ គម្រោងនេះបានផ្តល់ជំនួយផ្នែកហិរញ្ញវត្ថុដើម្បីរ៉ាប់រងថ្លៃសិក្សារបស់ពួកគេ រួមទាំងសម្ភារៈសិក្សា ឯកសណ្ឋាន ការចំណាយលើការធ្វើដំណើរ និងថ្លៃវគ្គសិក្សានានា។ លើសពីនេះ COCD ធ្វើសកម្មភាពដើម្បីជំរុញឱ្យមានចំណង់ចំណូលចិត្តក្នុងការរៀនសូត្រ និងជំរុញការយល់ដឹងអំពីតម្លៃនៃការអប់រំក្នុងចំណោមក្មេងស្រីទាំងនេះ។ ជាលទ្ធផល សិស្សចំនួន ២៦ (៨៦.៦៧%) ក្នុងចំណោមសិស្ស ៣០ នាក់ដែលបានទទួលអាហារូបករណ៍ បានប្រឡងជាប់ថ្នាក់ទី ១២។ លទ្ធផលនេះ បង្ហាញពីយុទ្ធសាស្ត្រ និងការខិតខំប្រឹងប្រែង ក្នុងការទប់ស្កាត់ការបោះបង់ការសិក្សារបស់អង្គការ COCD។

## ៤.៤.៣ ការតម្រង់ទិសអាជីពដំបូងដោយលោកស្រី ម៉ែន មករា នាយកប្រចាំប្រទេសនៅអង្គការដើម្បីភាពញញឹមនៃកុមារ (PSE)

នៅឆ្នាំ ២០២២ ក្រុមការងារទប់ស្កាត់ការបោះបង់ការសិក្សា ត្រូវបានបង្កើតឡើងនៅក្នុងអង្គការ PSE ដើម្បីធានាបាននូវការរៀនសូត្រជាបន្តបន្ទាប់សម្រាប់សិស្ស និងណែនាំពួកគេឆ្ពោះទៅរកវិជ្ជាជីវៈនាពេលអនាគត។ គោលបំណងរបស់ក្រុមការងារនេះរួមមានការកំណត់លក្ខណៈវិនិច្ឆ័យនៃការបោះបង់ការសិក្សានៅក្នុង PSE ការវិភាគមូលហេតុនៃការបោះបង់ការសិក្សា ការកំណត់អត្តសញ្ញាណសិស្សដែលមានហានិភ័យខ្ពស់ និងការបង្កើតផែនការសកម្មភាពដោយផ្អែកលើអាទិភាពទាំងនេះ។

### ការរកឃើញសំខាន់ៗ៖

- **គ្រួសារដែលមានប្រាក់ចំណូលទាប៖** ការបោះបង់ការសិក្សាបានធ្វើឲ្យប៉ះពាល់ខ្លាំងដល់កុមារមកពីគ្រួសារដែលមានចំណូលទាបបំផុត។
- **ក្រុមអាយុ៖** ការបោះបង់ការសិក្សាភាគច្រើនកើតឡើងក្នុងចំណោមសិស្សដែលមានអាយុពី ១៥-១៧ ឆ្នាំ (៤៧%) និងសិស្សដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ (៣៨%)។
- **ហេតុផលសម្រាប់ការបោះបង់ការសិក្សា៖** មូលហេតុទូទៅរួមមាន «មិនមានឆន្ទៈក្នុងការសិក្សា» និង «ការតែងតាំងការងារដែលមិនមានជំនាញ» (ដែលរួមបញ្ចូលកត្តាផ្សេងៗទៀត)។
- **ការថយចុះទំហំថ្នាក់៖** សិស្សក្នុងមួយថ្នាក់មានការថយចុះជាបន្តបន្ទាប់ពីថ្នាក់មួយទៅថ្នាក់មួយទៀត។

PSE បានអនុវត្តកម្មវិធីតម្រង់ទិសជំនាញ និងការណែនាំអំពីអាជីព ដើម្បីដោះស្រាយបញ្ហាទាំងនេះ និងដើម្បីលើកកម្ពស់លទ្ធផលសិស្ស។ កម្មវិធីនេះមានគោលបំណងបង្កើនការយល់ដឹងដោយខ្លួនឯង ធ្វើអោយប្រសើរឡើងនូវការចូលរួមសិក្សា ពង្រីកការយល់ដឹងអំពីអាជីព សម្រួលដល់ការសម្រេចចិត្តប្រកបដោយការយល់ដឹង ធ្វើអោយប្រសើរឡើងនូវការគ្រប់គ្រងខ្លួនឯង បង្កើនការត្រៀមខ្លួនក្នុងអាជីព អភិវឌ្ឍជំនាញក្នុងសតវត្សទី ២១ លើកកម្ពស់ការរួមបញ្ចូល និងកាត់បន្ថយអត្រាបោះបង់ការសិក្សា។ តាមរយៈការផ្តល់នូវការណែនាំអំពីអាជីពដ៏ទូលំទូលាយ PSE ជួយសិស្សានុសិស្សស្វែងយល់ពីចំណាប់អារម្មណ៍របស់ពួកគេ ភ្ជាប់ការសិក្សាក្នុងថ្នាក់រៀនទៅនឹងកម្មវិធីពិភពលោកពិត យល់អំពីគន្លងអប់រំ កំណត់គោលដៅ និងអភិវឌ្ឍជំនាញចាំបាច់សម្រាប់ភាពជោគជ័យនាពេលអនាគត។ ទិន្នន័យដំបូងពីគម្រោងសាកល្បងក្នុងឆ្នាំ ២០២៣ បានបង្ហាញពីលទ្ធផលដ៏ជោគជ័យក្នុងការកាត់បន្ថយភាពមិនច្បាស់លាស់របស់សិស្សអំពីផ្លូវនៃការអប់រំរបស់ពួកគេ ដោយបង្ហាញពីប្រសិទ្ធភាពនៃកម្មវិធីណែនាំអំពីអាជីពក្នុងការដោះស្រាយកង្វល់ពីការបោះបង់ការសិក្សា និងផ្តល់សិទ្ធិអំណាចដល់សិស្សក្នុងការសម្រេចចិត្តប្រកបដោយការយល់ដឹងអំពីអនាគតរបស់ពួកគេ។

### ៤.៤.៤ សំនួរ-ចម្លើយ

- នាយកដ្ឋានគោលនយោបាយ (DoPo) នៃក្រសួងអប់រំ យុវជន និងកីឡា (MoEYS) បានទទួលស្គាល់ថា ខណៈពេលដែលការស្រាវជ្រាវទទួលស្គាល់កត្តាខ្លួនឯងថាជាហេតុផលសក្តានុពលនៃការបោះបង់ការសិក្សា ការសិក្សាជាក់លាក់លើការប្រើប្រាស់គ្រឿងញៀននៅមានកង្វះខាត។ ទោះជាយ៉ាងណាក៏ដោយ លោកស្រីបានកត់សម្គាល់ថា កត្តាផ្សេងៗ រួមទាំងការប្រើប្រាស់គ្រឿងញៀន និងសម្ភារៈនិយម អាចរួមចំណែកដល់អត្រាបោះបង់ការសិក្សា។
- អ្នកចូលរួមម្នាក់បានលើកឡើងពីការព្រួយបារម្ភអំពីសិស្សក្រីក្រដែលមិនអាចមានលទ្ធភាពសិក្សាក្រៅម៉ោង ហើយបានសួរថា តើក្រសួងមានគោលការណ៍ដោះស្រាយរឿងនេះដែរឬទេ។ នាយកដ្ឋានគោលនយោបាយនៃក្រសួងអប់រំ យុវជន និងកីឡា ស្នើឱ្យដោះស្រាយបញ្ហាកង្វះគ្រូបង្រៀន និងការលំបាកក្នុងការសិក្សា គួរតែជាផ្នែកមួយនៃផែនការរបស់ក្រសួង។ ទោះជាយ៉ាងណាក៏ដោយ ការអនុវត្តការបង្រៀនពេញម៉ោងគឺត្រូវចំណាយច្រើន ដោយបង្កើតជាសំណួរអំពីមូលនិធិ និងផលប៉ះពាល់ដល់គ្រូបង្រៀន។ នាយដ្ឋានបបានលើកឡើងពីការពិនិត្យឡើងវិញជាបន្តបន្ទាប់នៃលទ្ធផលសិក្សា និងតួនាទីរបស់សហគមន៍ និងនាយកសាលាក្នុងការដោះស្រាយបញ្ហាទាំងនេះ។
- សំណួរមួយទៀតគឺវិធីសាស្រ្តដោះស្រាយបញ្ហាកង្វះគ្រូបង្រៀននៅតំបន់ដាច់ស្រយាល និងធានាគុណភាពនៃការបង្រៀនជាមួយគ្រូជាប់កិច្ចសន្យា។ នាយកដ្ឋានគោលនយោបាល នៃក្រសួងអប់រំ យុវជន និងកីឡា បានពន្យល់ថា ក្រសួងបានធ្វើការសិក្សាលើគ្រូបង្រៀនជាប់កិច្ចសន្យា ហើយបានរកឃើញតម្រូវការសម្រាប់តុល្យភាពរវាងគ្រូជាប់កិច្ចសន្យា និងគ្រូបង្រៀនអចិន្ត្រៃយ៍។ ខណៈពេលដែលគ្រូបង្រៀនជាប់កិច្ចសន្យាអាចខ្វះការបណ្តុះបណ្តាលគរុកោសល្យ អ្នកខ្លះធ្វើបានល្អ។ ទោះជាយ៉ាងណាក៏ដោយ គំនិតផ្តួចផ្តើមបណ្តុះបណ្តាលគឺធ្វើឡើងដើម្បីលើកកម្ពស់គុណភាពនៃការបង្រៀន ជាពិសេសនៅតំបន់ដាច់ស្រយាល។
- សំណួរមួយទៀតគឺអំពីការគាំទ្រដែលផ្តល់ដោយគម្រោង COCD ដល់សិស្សនៅតំបន់ដាច់ស្រយាល។ គម្រោង COCD ផ្តល់អាហារូបករណ៍ និងវាយតម្លៃតម្រូវការជាក់ស្តែងរបស់គ្រួសារ។ ពួកគេគាំទ្រការចិញ្ចឹមជីវិតតាមរយៈអាជីវកម្ម និងការធ្វើស្រែចំការ ផ្តល់ជំនួយអាហារប្រចាំខែ និងផ្តល់ប្រាក់ឧបត្ថម្ភការស្នាក់នៅរបស់សិស្ស រួមទាំងជំនួយការជួលសម្រាប់ក្រុមនិស្សិតពីរ ឬបីនាក់។
- សំណួរមួយទៀតគឺអំពីភាពជោគជ័យនៃអាហារូបករណ៍ក្នុងការកាត់បន្ថយអត្រាបោះបង់ការសិក្សារបស់សិស្ស។ អ្នកតំណាងមកពីអង្គការ PSE បានកត់សម្គាល់ថាកម្មវិធី PSE ទាំងអស់រួមចំណែកដល់ការកាត់បន្ថយអត្រាបោះបង់ការសិក្សា។ លើសពីនេះ អង្គការ PSE ផ្តល់ថ្នាក់បំប៉នសម្រាប់អ្នករៀនយឺត ឬសិស្សបោះបង់ការសិក្សា និងផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់អ្នកដែលចាកចេញពីសាលាមុនកំណត់។

## ៤.៥ វេទិកាពិភាក្សា៖ ជំនួយសាលារៀន

វេទិកាពិភាក្សាវគ្គនេះគូសបញ្ជាក់ពីសារៈសំខាន់នៃការជំរុញស្វ័យភាព និងយន្តការជួយខ្លួនឯងនៅក្នុងសាលារៀន ដោយបទបង្ហាញទាំងពីរនេះផ្តល់នូវការយល់ដឹងដ៏មានតម្លៃក្នុងការលើកកម្ពស់ស្ថិរភាពហិរញ្ញវត្ថុ ការចូលរួមសហគមន៍ និងសុខុមាលភាពសិស្ស។

### ៤.៥.១ ការជួយសាលារបស់យើង ដោយលោកបណ្ឌិត អ៊ុក អៀងគីម នាយកប្រតិបត្តិនៃអង្គការសាមគ្គី

ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមផ្នែកហិរញ្ញវត្ថុរបស់សាលារៀន អង្គការសាមគ្គី ណែនាំពីគំនិតផ្តួចផ្តើមមូលនិធិគាំទ្រសាលា ក្នុងគោលបំណងលើកកម្ពស់ស្ថិរភាពសេដ្ឋកិច្ច និងលើកភាពជាម្ចាស់របស់សហគមន៍។ គំនិតផ្តួចផ្តើមនេះបង្កើតកម្មវិធីដែលមានរចនាសម្ព័ន្ធគ្រប់គ្រងដោយច្បាប់ និងគោលការណ៍ណែនាំ ដោយផ្តោតសាលារៀនកម្រិតបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ។ វិធីសាស្ត្រនេះពាក់ព័ន្ធនឹងរចនាសម្ព័ន្ធគណៈកម្មាធិការដែលរួមមានប្រធាន អនុប្រធាន និងសមាជិកទីមួយ និងមានការចូលរួមយ៉ាងសកម្មពីមាតាបិតា លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស។ ការរកឃើញសំខាន់ៗដែលធ្វើឱ្យដំណើរការនៃគោលការនេះមានដូចជា ការបង្កើតកិច្ចប្រជុំប្រចាំត្រីមាស និងប្រចាំឆ្នាំ ប្រភពមូលនិធិចម្រុះ និងវិធីសាស្ត្រជាប្រព័ន្ធក្នុងការគ្រប់គ្រងមូលនិធិ។ ជាកិច្ចបញ្ចប់ លោកបានអំពាវនាវឱ្យមានសកម្មភាព តស៊ូមតិសម្រាប់ការអនុម័តកម្មវិធីមូលនិធិគាំទ្រសាលារៀន ដើម្បីជានាការផ្តល់មូលនិធិប្រកបដោយនិរន្តរភាព តម្លាភាពហិរញ្ញវត្ថុ និងការចូលរួមពីសហគមន៍។ គំនិតផ្តួចផ្តើមនេះដោះស្រាយតម្រូវការហិរញ្ញវត្ថុភ្លាមៗ និងលើកកម្ពស់វប្បធម៌សហការ និងសកម្មនៅក្នុងសហគមន៍សាលារៀន។

### ៤.៥.២ មធ្យោបាយធ្វើដំណើរ ពីផ្ទះទៅសាលារៀន ដោយលោក ពេជ្រ សុវណ្ណ អ្នកគ្រប់គ្រងកម្មវិធីនៅអង្គការសុវណ្ណភូមិ

កម្មវិធីមធ្យោបាយធ្វើដំណើរមានគោលបំណងជួយសម្រួលដល់សិស្សានុសិស្ស ដែលប្រឈមនឹងការបោះបង់ការសិក្សា ដោយកត្តាការរស់នៅឆ្ងាយពីសាលារៀន ដើម្បីអាចទៅសាលារៀនបានទៀងទាត់។ គំនិតផ្តួចផ្តើមនេះបានផ្តល់នូវមធ្យោបាយធ្វើដំណើរប្រកបដោយក្តីសង្ឃឹម និងការជឿទុកចិត្តដល់មាតាបិតា/អាណាព្យាបាលសិស្ស ដើម្បីគាំទ្រកម្មវិធីនេះសម្រាប់និរន្តរភាពនាពេលអនាគតបន្តិចម្តងៗ។ នីតិវិធីរួមមាន នាយកសាលាដែលស្នើកម្មវិធី បង្កើតរចនាសម្ព័ន្ធសម្រាប់ការអនុវត្ត កំណត់អត្តសញ្ញាណសិស្សដែលខ្វះខាតមធ្យោបាយធ្វើដំណើរ និងរៀបចំកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធដើម្បីពិភាក្សាពីតម្រូវការ និងស្វែងរកអ្នកផ្តល់សេវា។ នៅពេលដែលអ្នកផ្តល់សេវាត្រូវបានជ្រើសរើស តួនាទី និងការទទួលខុសត្រូវត្រូវបានបញ្ជាក់ឱ្យច្បាស់លាស់ ហើយកាលវិភាគដឹកជញ្ជូន និងកិច្ចព្រមព្រៀងត្រូវបានកំណត់។ បន្ទាប់មក កម្មវិធីនេះត្រូវបានដាក់ឱ្យដំណើរការ ដោយមានការត្រួតពិនិត្យជាប្រចាំ និងការឆ្លុះបញ្ចាំងពីសិស្ស ឪពុកម្តាយ លោកគ្រូ អ្នកគ្រូ នាយកសាលា គណៈកម្មាធិការគ្រប់គ្រង និងអ្នកផ្តល់សេវា។ លទ្ធផលរួមមានការចូលសាលាជាទៀងទាត់សម្រាប់សិស្សទាំងអស់ និងអត្រាជាប់មានចំនួនរហូតដល់ ៨៤% សម្រាប់សិស្សដែលបានចុះឈ្មោះក្នុងកម្មវិធីដឹកជញ្ជូន។

### ៤.៥.៣ សំនួរ-ចម្លើយ

អ្នកចូលរួមបានសួរសំណួរទៅកាន់វាគ្មិនទាក់ទងនឹងការអនុវត្តល្អៗ សម្រាប់ការបង្កើតមូលនិធិសាលារៀនយុទ្ធសាស្ត្រសម្រាប់ការចូលរួមសហគមន៍ និងការអនុវត្តត្រឹមត្រូវនៃគំនិតផ្តួចផ្តើមរៃអង្គាសប្រាក់របស់សាលារៀន។ វាគ្មិនបានលើកឡើងពីសារៈសំខាន់នៃការកសាងទំនុកចិត្តក្នុងសហគមន៍ ការលើកកម្ពស់ការយល់ដឹងអំពីតម្លៃនៃការអប់រំសម្រាប់កូនរបស់ពួកគេ តម្លាភាពក្នុងការគ្រប់គ្រងមូលនិធិ ការចូលរួមពីសហគមន៍ក្នុងការសម្រេចចិត្ត និងការអនុវត្តតាមគោលការណ៍ណែនាំសម្រាប់សកម្មភាពរៃអង្គាសប្រាក់។

## ៤.៦ វេទិកាពិភាក្សា៖ គណនេយ្យភាពសង្គមលើស្តង់ដារបណ្ណាល័យ និងគំរូវគ្គសិក្សា 8 សប្តាហ៍មុនបឋមសិក្សា

វគ្គនេះបានបង្ហាញពីការធ្វើបទបង្ហាញដោយអង្គការទស្សនៈពិភពលោកនៅកម្ពុជា (WVI-C) និងអង្គការផ្លែន (Plan International) ដោយផ្តោតលើគំនិតផ្តួចផ្តើមក្នុងការកែលម្អស្តង់ដារបណ្ណាល័យ និងអនុវត្តកម្មវិធីអប់រំមត្តេយ្យសិក្សា។

### ៤.៦.១ គណនេយ្យភាពសង្គមលើស្តង់ដារបណ្ណាល័យ ដោយលោកស្រី ណុប ស្រីល័ក្ខ អ្នកឯកទេសបច្ចេកទេសនៃអង្គការទស្សនៈពិភពលោកអន្តរជាតិកម្ពុជា (WVI-C)

គំនិតផ្តួចផ្តើមនេះកើតចេញពីការបង្កើតទិវាជាតិអំណានឆ្នាំ ២០១៦ របស់រាជរដ្ឋាភិបាល ដើម្បីលើកកម្ពស់អក្ខរកម្ម។ ជារៀងរាល់ឆ្នាំ អង្គការទស្សនៈពិភពលោកនៅកម្ពុជា តម្រឹមតាមគំនិតផ្តួចផ្តើមនេះ ដើម្បីតស៊ូមតិឱ្យមានភាពប្រសើរឡើងនូវបណ្ណាល័យសហគមន៍។ គោលបំណងរួមមានការលើកកម្ពស់គុណភាពបណ្ណាល័យតាមរយៈដំណើរការគណនេយ្យភាពសង្គម ការលើកកម្ពស់ការយល់ដឹងអំពីស្តង់ដារបណ្ណាល័យជាតិក្នុងចំណោមសហគមន៍ និងការជំរុញការប្តេជ្ញាចិត្តពីអ្នកធ្វើការសម្រេចចិត្តក្នុងការកែលម្អបណ្ណាល័យ។ ដំណើរការនេះពាក់ព័ន្ធនឹងការផ្តល់សិទ្ធិអំណាចដល់សិស្ស និងមាតាបិតា ការកំណត់បញ្ហា និងការរៀបចំផែនការសកម្មភាពតាមរយៈកិច្ចសន្ទនា។ ព្រឹត្តិការណ៍ប្រារព្ធពិធីបង្ហាញពីផែនការសកម្មភាពទាំងនេះ ជំរុញឱ្យមានការចូលរួមពីសហគមន៍ ដោយភាពសប្បាយរីករាយ។ ក្រោយព្រឹត្តិការណ៍ មានសកម្មភាពបន្តទៀតគឺការរាយការណ៍ និងការតាមដាន និងការធានានូវការទទួលខុសត្រូវ។ លទ្ធផលបង្ហាញថា សាលារៀនជាច្រើនខ្វះបណ្ណាល័យស្តង់ដារ ទីធ្លាសម្រាប់អាន។ ការពង្រឹងអំណាចក្នុងចំណោមកុមារ និងសហគមន៍បានកើនឡើង ដែលនាំឱ្យមានកិច្ចខិតខំប្រឹងប្រែងរួមគ្នាដើម្បីកែលម្អបណ្ណាល័យ។ ការព្រួយបារម្ភនៅតែមានទាក់ទងនឹងលទ្ធភាពទទួលបានសម្ភារៈអាន និងលទ្ធភាពទិញសៀវភៅសម្រាប់ជំនួយសិស្ស ជំរុញឱ្យមានការផ្តល់យោបល់សម្រាប់ការសាងសង់/កែលម្អអគារបណ្ណាល័យ ដួលបណ្ណារក្សលើកកម្ពស់បរិយាកាសដែលសំបូរទៅដោយបោះពុម្ព និងការផ្តល់សម្ភារៈអានគ្រប់គ្រាន់ និងសៀវភៅជំនួយដល់សិស្សដែលខ្វះខាត។

## ការរកឃើញ

- សាលារៀនភាគច្រើនដែលប្រារព្ធទិវាជាតិអំណានមិនមានអាគារបណ្ណាល័យស្តង់ដារនោះទេ។ គណកម្មាធិការគ្រប់គ្រងសាលាបានបែងចែកថ្នាក់រៀនមួយជាទីកន្លែងអាន ដើម្បីលើកកម្ពស់ទម្លាប់អានរបស់សិស្ស។
- កុមារ និងសហគមន៍ក៏មានការព្រួយបារម្ភអំពីការទិញសៀវភៅជំនួយសិស្ស ដោយសារសិស្សជាច្រើនមិនអាចមានលទ្ធភាពទិញបាន ដែលប៉ះពាល់ដល់ការសិក្សារបស់សិស្ស។

### ៤.៦.២ គំរូវគ្គសិក្សា ៨ សប្តាហ៍មុនបឋមសិក្សា ដោយលោក សៀង សុភ័ក្រ អ្នកគ្រប់គ្រងគម្រោងនៅអង្គការផ្លែន (Plan International)

កម្មវិធី PPE អនុវត្តដោយអង្គការ ផ្លែន គឺជាកម្មវិធីរយៈពេល ៨ សប្តាហ៍ដែលផ្តល់ជូនក្នុងអំឡុងពេលវិស្សមកាល មុនពេលឆ្នាំសិក្សាថ្មីចាប់ផ្តើម។ កម្មវិធីនេះគឺជាការទទួលយកពីគំរូដែលមានភាពស្រដៀងគ្នា បង្កើតឡើងដោយមូលនិធិអប់រំកុមារមាតា (AÇEV) នៅក្នុងប្រទេសទួគី។ កម្មវិធីនេះផ្តោតលើក្មេងប្រុស និងក្មេងស្រីមកពីសហគមន៍ជនជាតិភាគតិចនៅតំបន់ដាច់ស្រយាលដែលចុះឈ្មោះចូលរៀននៅថ្នាក់ទី ១ ដែលមិនមានការអប់រំមុនបឋមសិក្សា ឬមត្តេយ្យសិក្សា។ កម្មវិធីនេះផ្តល់ជូនដោយគ្រូថ្នាក់ទី១ ឬបឋមសិក្សា និងគាំទ្រដោយប្រធានសាលា និងបុគ្គលិកអប់រំយុវជន និងកីឡាស្រុក។ កម្មវិធីនេះមានគោលបំណងគាំទ្រដល់ការអភិវឌ្ឍរួមរបស់កុមារ និងការត្រៀមខ្លួនរបស់សាលា ហើយផ្តោតលើផ្នែកអភិវឌ្ឍចំនួន៤៖ រាងកាយ ភាសា ការយល់ដឹង និងសង្គម-អារម្មណ៍។

### ៤.៦.៣ សំនួរ-ចម្លើយ

- អ្នកចូលរួមបានសួរសំណួរទៅកាន់វាគ្មិនទាក់ទងនឹងលទ្ធផល និងនិរន្តរភាពនៃ WPP។ សំណួរមួយផ្តោតលើភាពខុសគ្នារវាងសិស្សដែលបានចូលរួមក្នុងកម្មវិធីនេះ និងអ្នកដែលមិនបានចូលរួម។ ជាការឆ្លើយតប វាត្រូវបានកត់សម្គាល់ឃើញថា សិស្សដែលបានឆ្លងកាត់កម្មវិធីនេះបានបង្ហាញពីកម្រិតខ្ពស់នៃការយល់ដឹង និងទំនុកចិត្ត ដែលរៀបចំឱ្យពួកគេកាន់តែប្រសើរឡើងសម្រាប់ការចូលរៀនថ្នាក់ទីមួយ។ លើសពីនេះ មាតាបិតាសិស្សដែលចូលរួមក៏ទទួលបានចំណេះដឹងដ៏មានតម្លៃអំពីកម្មវិធីផងដែរ។
- អ្នកចូលរួមម្នាក់ទៀតបានលើកសំនួរ ទាក់ទងនឹងយន្តការដែលបង្កើតឡើងដោយអង្គការទស្សនៈពិភពលោកអន្តរជាតិ (WVI) ដើម្បីធានានិរន្តរភាពនៃប្រតិបត្តិការបណ្ណាល័យ។ ជាងនេះទៅទៀត អ្នកចូលរួមបានស្វែងរកការបំភ្លឺអំពីថាតើការរៀបចំបណ្ណាល័យស្តង់ដារបានពិចារណាលើកត្តាមួយចំនួនដូចជាពិការភាព និងបរិស្ថាន និងការកំណត់អត្តសញ្ញាណធនធានខ្វះខាតដែរឬទេ។ ការឆ្លើយតបបានបង្ហាញពីការប្តេជ្ញាចិត្តរបស់ WVI ចំពោះនិរន្តរភាព តាមរយៈយន្តការលើកកម្ពស់ការអនុវត្តគោលនយោបាយ និងការដោះស្រាយបញ្ហានៅក្នុងក្រុមការងារអប់រំ។ ទាក់ទងនឹងស្តង់ដារបណ្ណាល័យ គេកត់សម្គាល់ថា ខណៈពេលដែល

WVI ប្រកាន់ខ្ជាប់នូវស្តង់ដារបណ្ណាល័យបឋមរបស់ក្រសួងអប់រំឆ្នាំ ២០១១ វាមានតម្រូវការក្នុងការតស៊ូមតិសម្រាប់ការកែប្រែរបស់ខ្លួនដើម្បីរួមបញ្ចូលការគាំទ្រសម្រាប់បុគ្គលពិការ។

## ៤.៧ វេទិកាពិភាក្សា៖ ការលើកកម្ពស់ការបណ្តុះបណ្តាលគ្រូភាសាអង់គ្លេស និងការអភិវឌ្ឍវិជ្ជាជីវៈប្រចាំ (CPD)

វគ្គនេះបានចាប់ផ្តើមជាមួយនឹងបទបង្ហាញពីវាគ្មិនចំនួនបី ដែលផ្តោតលើការបណ្តុះបណ្តាលគ្រូភាសាអង់គ្លេស គំនិតផ្តួចផ្តើមការអប់រំឌីជីថល និងការត្រួតពិនិត្យការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (CPD) ។ វេទិកាពិភាក្សាបានគូសបញ្ជាក់ពីកិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់អង្គការនានាក្នុងការលើកកម្ពស់ការបណ្តុះបណ្តាលគ្រូភាសាអង់គ្លេស លើកកម្ពស់ការអប់រំបែបឌីជីថល និងតាមដានការផ្តួចផ្តើម ការអភិវឌ្ឍវិជ្ជាជីវៈជាបន្ត ដើម្បីកែលម្អលទ្ធផលអប់រំនៅកម្ពុជា។

### ៤.៧.១ វគ្គបណ្តុះបណ្តាលគ្រូភាសាអង់គ្លេស ដោយលោក ស៊ុន ណាត នាយកប្រតិបត្តិនៃអង្គការគាំទ្រការអភិវឌ្ឍន៍គ្រូបង្រៀន (TDSO)

ដើម្បីបង្កើនគុណភាពនៃកម្មវិធីបណ្តុះបណ្តាល និងការបង្វឹក ការប្រឹក្សាណែនាំរបស់ខ្លួន អង្គការ TDSO កំពុងបង្កើតក្របខ័ណ្ឌសម្រាប់ភាសាអង់គ្លេសថ្នាក់ទី ៤-៦ ។ ក្របខ័ណ្ឌនេះមានគោលបំណងជានាឱ្យមានការបន្សីគ្នារវាងសមាសធាតុសំខាន់ៗដូចជា លទ្ធផលសិក្សាវគ្គ (ដោយប្រើសៀវភៅសិក្សារបស់ក្រសួង អ.យ.ក) វិធីសាស្រ្តបង្រៀនផ្សេងៗ និងឧបករណ៍វាយតម្លៃ។ ដើម្បីជួយក្នុងការអនុវត្តបច្ចេកទេស ឬវិធីសាស្រ្តដែលបានស្នើឡើងក្នុងក្របខណ្ឌក្រុមការងាររៀបចំសម្ភារៈមេរៀនផ្សេងៗដូចជានីតិវិធីហ្គេម កាតបង្ហាញ សន្លឹកកិច្ចការ ទៅតាមតម្រូវការរបស់សិស្ស និងលក្ខណៈនៃមេរៀន។ អ្នកសិក្សាអាចចូលប្រើប្រាស់ធនធានទាំងនោះបានតាមរយៈគេហទំព័រ EduBox របស់អង្គការ TDSO ដែលសម្ភារៈទាំងអស់ត្រូវបានចាត់ថ្នាក់ដោយផ្អែកលើថ្នាក់ (៤-៦) និងឯកតា។ ឧបករណ៍នេះអាចដោះស្រាយកង្វល់ដែលតែងតែលើកឡើងថា «គ្រូខ្លះបង្រៀនសៀវភៅ មិនមែនបង្រៀនសិស្ស» និងការលើកឡើងថា «គ្រូខ្លះចេះវិធីបង្រៀន តែមិនដឹងបង្រៀនអំពីអ្វី»។

### ៤.៧.២ ថ្នាលអភិវឌ្ឍសមត្ថភាព (CDP) ដោយលោក ចាន់មុនី អ៊ុង អ្នកគ្រប់គ្រងអង្គភាព M&E នៃអង្គការអប់រំពិភពលោក (World Education)

ស្របតាមអាទិភាពជាតិរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងខែកញ្ញា ឆ្នាំ ២០២២ អង្គការអប់រំពិភពលោក (WE) ក្រោមមូលនិធិភាពជាដៃគូអភិវឌ្ឍសមត្ថភាព (CDPF III) ដើម្បីគាំទ្រក្រសួងអប់រំ និងនាយកដ្ឋានព័ត៌មានវិទ្យា (DIT) ដើម្បីបង្កើនបរិយាកាសសិក្សាឌីជីថលសម្រាប់អ្នកអប់រំ និងបុគ្គលិកអប់រំតាមរយៈ ការអភិវឌ្ឍថ្នាលអនឡាញដែលមានលក្ខណៈសមាហរណកម្ម និងមានគុណភាពខ្ពស់ សម្រាប់ការការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (CPD) និងប្រព័ន្ធផ្តល់ក្រេឌីត។ ចក្ខុវិស័យនៃគម្រោងនេះគឺបង្កើតវេទិកាមួយដែលមានឈ្មោះថា ថ្នាលអភិវឌ្ឍសមត្ថភាព (CDP) ដែលរៀបចំវគ្គបណ្តុះបណ្តាលដែលមានផ្តល់ក្រឌីត និងមិនមានក្រេឌីតសម្រាប់គ្រូបង្រៀន អ្នកបណ្តុះបណ្តាលគ្រូបង្រៀន អ្នកគ្រប់គ្រងសាលា មន្ត្រីអប់រំ និងបុគ្គលិកអប់រំផ្សេងទៀតនៅទូទាំងប្រព័ន្ធអប់រំនៅកម្ពុជា។ លើសពីនេះ

ថ្នាលនេះបានរួមបញ្ចូលជាមួយប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្សក្នុងប្រទេស (HRMIS) ដែលអនុញ្ញាតឱ្យមានការរួមបញ្ចូលយ៉ាងរលូន និងការតាមដានក្រេឌីតនៃការអប់រំបន្តសម្រាប់វគ្គសិក្សានានា និងលិខិតទទួលស្គាល់សមត្ថភាពផ្សេងៗទៀត។ ថ្នាលនេះក៏នេះមានគោលបំណងផ្តល់នូវការអភិវឌ្ឍវិជ្ជាជីវៈ និងឱកាសសិក្សាដោយផ្អែកលើជំនាញ និងសម្រួលដល់គន្លងអាជីពសម្រាប់អ្នកអប់រំទូទាំងប្រទេស។

### ៤.៧.៣ ការត្រួតពិនិត្យ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (CPD) ដោយលោក ៧ គឿង នាយកប្រចាំប្រទេសនៃអង្គការទស្សនៈឥតព្រំដែន (SeeBeyond Borders)

ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនបានលេចចេញជាអាទិភាពសកល ដោយការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (CPD) គឺជាមូលដ្ឋានគ្រឹះនៃគំនិតផ្តួចផ្តើមក្នុងការកែលម្អលទ្ធផលសិក្សារបស់កុមារនៅក្នុងប្រទេសកម្ពុជា។ ចាប់តាំងពីឆ្នាំ ២០១៧ មក ក្រសួង អ.យ.ក បានអនុវត្តយ៉ាងឆាប់រហ័សនូវគោលនយោបាយ គោលការណ៍ណែនាំ និងការលើកទឹកចិត្តដើម្បី ជម្រុញឱ្យមានការចូលរួមរបស់គ្រូបង្រៀននៅក្នុងសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។ អង្គការទស្សនៈឥតព្រំដែន បានធ្វើការត្រួតពិនិត្យយ៉ាងម៉ត់ចត់លើការស្រាវជ្រាវ និងរបាយការណ៍ដែលផ្តោតលើកត្តាដែលជះឥទ្ធិពលដល់ការចូលរួមរបស់គ្រូបង្រៀននៅក្នុងកម្មវិធី អភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ នៅក្នុងប្រទេសកម្ពុជា។ ការសិក្សាបានអង្កេតលើទស្សនៈរបស់គ្រូបង្រៀនលើការអភិវឌ្ឍវិជ្ជាជីវៈ ជាពិសេសការលើកទឹកចិត្ត និងចំណូលចិត្តរបស់ពួកគេចំពោះគំរូ និងរចនាសម្ព័ន្ធ CPD ។ ការរកឃើញ បានបង្ហាញថា គ្រូបង្រៀនកម្ពុជាមានការលើកទឹកចិត្តខាងក្នុង និងខាងក្រៅដើម្បីបន្តការសិក្សា CPD ដោយពួកគេជឿជាក់ថាការបន្តសិក្សា CPD មានឥទ្ធិពលវិជ្ជមានទៅលើការសិក្សារបស់សិស្ស។ ទាក់ទងនឹងគំរូ CPD គ្រូបង្រៀនពេញចិត្ត ការបណ្តុះបណ្តាលផ្ទាល់មុខ សិក្ខាសាលាបែបអន្តរកម្ម ដែលផ្តោតលើវិធីសាស្ត្របង្រៀន និងធនធាននានា។ ទោះជាយ៉ាងណាក៏ដោយ ពួកគេក៏បានបង្ហាញពីចំណាប់អារម្មណ៍លើគំនិតផ្តួចផ្តើម CPD លើអ៊ីនធឺណិត និងកំពុងរង់ចាំការកែលម្អនៅក្នុងហេដ្ឋារចនាសម្ព័ន្ធក្នុងបច្ចេកវិទ្យានេះ និងត្រៀមទទួលយកនូវចំណេះដឹងឌីជីថល។ ជាការផ្តល់ អនុសាសន៍ ក្រសួងអ.យ.ក គួរបង្កើនចេញផ្សាយម៉ោងសិក្សាសម្រាប់ CPD និងផ្តល់សំណងឬជំនួយ សម្រាប់ពេលវេលារបស់គ្រូបង្រៀនដែលឆ្លៀតពេលពីការងារផ្សេងៗ។ អង្គការទស្សនៈឥតព្រំដែន បានគូសបញ្ជាក់អំពីយុទ្ធសាស្ត្រជាច្រើនសម្រាប់ឆ្លើយតបទៅនឹងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ រួមមាន ការរៀបចំសិក្ខាសាលាដោយផ្អែកលើគោលការណ៍សិក្សាសម្រាប់មនុស្សពេញវ័យ ការបង្កើតសហគមន៍នៃការអនុវត្ត និងការទទួលស្គាល់អត្តសញ្ញាណគ្រូបង្រៀននៅក្នុងកម្មវិធី CPD ដើម្បីជំរុញស្វ័យភាព និងការកសាងសមត្ថភាពក្នុងចំណោមអ្នកដឹកនាំសាលា ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែង CPD របស់គ្រូបង្រៀន។ ទោះបីជាយ៉ាងណាក៏ដោយ បញ្ហាប្រឈមត្រូវបានកត់សម្គាល់ ដូចជាកង្វះសក្តានុពលរបស់គ្រូក្នុងការយល់ដឹងអំពីបុព្វហេតុរបស់ CPD និងតម្រូវការសម្រាប់វិធីសាស្ត្រដ៏ទូលំទូលាយ ដែលមិនត្រឹមតែផ្តល់នូវការណែនាំណែនាំប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសង្កត់ធ្ងន់ទៅលើការយល់ចិត្ត និងការលើកទឹកចិត្តផងដែរ។ ជាចុងក្រោយ អង្គការទស្សនៈឥតព្រំដែន បានស្នើឱ្យក្រសួងអ.យ.ក ទទួលស្គាល់ជាផ្លូវការរាល់អង្គការក្រៅរដ្ឋាភិបាលណាដែលផ្តល់សេវា CPD ប្រកបដោយគុណភាព ដូចជាអង្គការរបស់ខ្លួនជាដើម។

## ៤.៨ វេទិកាពិភាក្សាស្តីពី៖ ហិរញ្ញប្បទានវិស័យអប់រំ

វេទិកាពិភាក្សាវគ្គនេះបានលើកឡើងពីយុទ្ធសាស្ត្រហិរញ្ញប្បទានអប់រំនៅកម្ពុជា ដោយផ្តោតលើតម្លាភាព និងការចូលរួមពីសហគមន៍។ អង្គការទស្សនៈពិភពលោកបានណែនាំឧបករណ៍ត្រួតពិនិត្យថវិការបស់សាលាដែលត្រូវបានហៅថា ក្របខ័ណ្ឌគណនេយ្យភាពសង្គម(ISAF) ដើម្បីលើកកម្ពស់តម្លាភាព និងការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងការងារថវិកាបឋមសិក្សា។ មូលនិធិសមធម៌ សាលារៀន ដែលដឹកនាំដោយនាយកដ្ឋានបឋមសិក្សា មានគោលបំណងធ្វើឱ្យប្រសើរឡើងនូវលទ្ធផលសិក្សា និងលើកកម្ពស់គុណភាពបង្រៀនតាមរយៈកម្មវិធីសាលារៀនផ្សេងៗ។ បញ្ហាប្រឈមនៃកម្មវិធីនេះរួមមានការចូលរួមរបស់មាតាបិតានៅមានកម្រិតទៀប និងសមាហរណកម្មបច្ចេកវិទ្យាប្រកបដោយប្រសិទ្ធ ភាព។ ជាមួយគ្នានេះដែរ នាយកដ្ឋានមានផែនការលើកកម្ពស់ការចូលរួមសហគមន៍ និងការអភិវឌ្ឍជំនាញសម្រាប់គ្រូបង្រៀន និងសិស្សដើម្បីបង្កើនប្រសិទ្ធភាពមូលនិធិនេះ។

### ៤.៨.១ ឧបករណ៍ត្រួតពិនិត្យថវិការបស់សាលា ISAF ដោយលោកស្រី យិន សុភ័ណ្ឌ ប្រធានផ្នែកតស៊ូមតិនៅអង្គការទស្សនៈពិភពលោក (WVI)

WVI បានបង្កើតឧបករណ៍ឌីជីថលសម្រាប់ត្រួតពិនិត្យថវិកាសាលាបឋមសិក្សា ដោយអនុវត្តក្របខ័ណ្ឌគណនេយ្យភាពសង្គម(ISAF)តាមរយៈអាសយដ្ឋានគេហទំព័រ៖ https://mis.ncdd.gov.kh/isaf/km/PostOnPrimarySchool។ គេហទំព័រនេះអាចអនុញ្ញាតឱ្យសាធារណៈជនចូលប្រើប្រាស់ថវិកាសាលាបឋមសិក្សាសម្រាប់ចំណូល និងចំណាយក្នុងតំបន់គោលដៅគម្រោង។ វាសង្កត់ធ្ងន់ទៅលើតម្លាភាព ការចូលរួមរបស់ប្រជាពលរដ្ឋ និងការឆ្លើយតបទៅនឹងតម្រូវការសហគមន៍។ សម្រាប់សាលាបឋមសិក្សា កញ្ចប់ព័ត៌មានរួមមានទំហំថ្នាក់ ប្រេកង់មេរៀន ការផ្តល់សៀវភៅសិក្សា អត្រាចូលរៀនរបស់សិស្ស និងភាគរយនៃការបញ្ចប់។ វាក៏គូសបញ្ជាក់អំពីអាទិភាពសម្រាប់ការកែលម្អសាលារៀន រួមទាំងសម្ភារៈបរិក្ខារ សម្ភារៈបង្រៀន និងការគាំទ្រសិស្សផងដែរ។

### ៤.៨.២ មូលនិធិសមធម៌សម្រាប់សាលារៀន ដោយលោក កែវ នរិទ្ធ ប្រធានការិយាល័យផែនការ និងសហប្រតិបត្តិការនៃនាយកដ្ឋានអប់រំបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា

មូលនិធិសមធម៌ ដែលប្រមូលបានពីគ្រួសារសិស្សនៅកម្រិតសហគមន៍ និងសាលារៀន មានគោលបំណងធ្វើឱ្យប្រសើរឡើងនូវលទ្ធផលសិក្សារបស់សិស្ស លើកកម្ពស់គុណភាពបង្រៀន លើកកម្ពស់ការគ្រប់គ្រងសាលារៀន និងបង្កើនការចូលរួមរបស់សហគមន៍តាមរយៈការប្រើប្រាស់មូលនិធិដើម្បីគាំទ្រនូវសកម្មភាពនានារបស់សាលារៀន ដូចជាអាហារពេលព្រឹកនៅសាលារៀន សកម្មភាពក្រៅកម្មវិធីសិក្សា និងការអនុវត្តកម្មវិធីសិក្សាក្រៅម៉ោង។ លើសពីនេះ មូលនិធិនេះមានគោលដៅ ការកែលម្អការចូលរួម និងការរក្សាសិស្ស ការលើកកម្ពស់លទ្ធផលសិក្សា ការលើកកម្ពស់អាហារូបត្ថម្ភ និងអាកប្បកិរិយារបស់សិស្ស និងការពង្រឹងគុណភាពបង្រៀន បង្កើនការចូលរួមរបស់សហគមន៍ក្នុងការគ្រប់គ្រង និងប្រតិបត្តិការរបស់សាលាផងដែរ។ សកម្មភាពសិក្សាក្រៅម៉ោងត្រូវបានចាប់ផ្តើមដើម្បីបង្កើនពេល

វេលាសិក្សារបស់សិស្ស អភិវឌ្ឍទម្លាប់សិក្សាឯករាជ្យរបស់សិស្ស និងរៀបចំជំនាញទន់ដែលចាំបាច់សម្រាប់ជីវិត និងការងារដល់សិស្ស។

មុននឹងចាប់ផ្តើមសកម្មភាពសិក្សាក្រៅម៉ោង សាលារៀនត្រូវតែបង្កើតភាពជាដៃគូ ជ្រើសរើសគ្រូបង្រៀនដែលមានជំនាញ ផ្សព្វផ្សាយព័ត៌មានដល់សិស្ស និងមាតាបិតា និងរៀបចំគណៈកម្មាធិការពាក់ព័ន្ធ។ ក្នុងអំឡុងពេលសកម្មភាពទាំងនេះ គ្រូបង្រៀន និងបុគ្គលិកសាលាសហការគ្នាដើម្បីដឹកនាំសិស្ស ខណៈដែលគណៈកម្មាធិការគ្រប់គ្រងត្រួតពិនិត្យការសម្របសម្រួលជាមួយអង្គការគាំទ្រ។ បញ្ហាប្រឈមនៃកម្មវិធីនេះរួមមានការចូលរួមរបស់មាតាបិតានៅមានកម្រិតទាប ការធ្វើសមាហរណកម្មបច្ចេកវិជ្ជារបស់គ្រូបង្រៀននៅមានកម្រិត និងចំណេះដឹងមិនគ្រប់គ្រាន់ក្នុងចំណោមនាយកសាលាក្នុងការបង្កើតគណៈកម្មាធិការគ្រប់គ្រង។

ទោះជាយ៉ាងណាក៏ដោយ ទិសដៅប្រកបដោយភាពច្នៃប្រឌិតសម្រាប់អនាគតរួមមានការពង្រីកសកម្មភាពសិក្សាក្រៅម៉ោង ការលើកកម្ពស់សុខភាពសិក្សា និងការបណ្តុះបណ្តាលគ្រូ និងសិស្សក្នុងជំនាញសតវត្សទី ២១ ។ ផែនការសកម្មភាពបន្ទាប់ពាក់ព័ន្ធនឹងការលើកកម្ពស់ការចូលរួមរបស់សហគមន៍បន្ថែមទៀត ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងការពង្រឹងជំនាញគ្រូបង្រៀន សិស្ស ដើម្បីបង្កើនប្រសិទ្ធភាពនៃមូលនិធិសមធម៌សម្រាប់សាលារៀន។

### ៤.៨.៣ សំនួរ-ចម្លើយ

- វាគ្មិនបានសង្កត់ធ្ងន់លើសារៈសំខាន់នៃការសន្ទនារបស់អ្នកពាក់ព័ន្ធក្នុងការតស៊ូមតិសម្រាប់ការកើនឡើងនៃការបែងចែកថវិកា។ សំណួរត្រូវបានលើកឡើងអំពីលទ្ធផលនៃការអនុវត្ត ISAF ដោយការឆ្លើយតបបានកត់សម្គាល់ថាបច្ចុប្បន្នមិនមានផលប៉ះពាល់វិជ្ជមានអ្វីច្រើនទេ ប៉ុន្តែផែនការរបស់សាលាគឺអាចសម្រេចបាន ៧0% ។ ការចំណាយនានាអាចត្រូវបានផ្ទៀងផ្ទាត់នៅលើគេហទំព័ររបស់ឧបករណ៍ ISAF។
- ក្រសួងបានរៀបចំថវិកា និងទទួលបានការវិភាគពីក្រសួងសេដ្ឋកិច្ច ដែលត្រូវតែអនុវត្តតាមផែនការប្រតិបត្តិការប្រចាំឆ្នាំឱ្យបានជិតដល់។ ទោះយ៉ាងណាក៏ដោយ វាអាចមានភាពបត់បែនខ្លះក្នុងការចំណាយ ព្រោះជាតុមួយចំនួនគ្រាន់តែជាឧទាហរណ៍ប៉ុណ្ណោះ ហើយការចំណាយត្រូវតែស្របតាមថវិកា។
- អ្នកចូលរួមក៏បានសាកសួរអំពីសមធម៌ក្នុងការអនុវត្តមូលនិធិសមធម៌សម្រាប់សាលារៀនផងដែរ។ គន្លឹះនៃការអនុវត្តប្រកបដោយជោគជ័យគឺការបង្កើតយន្តការគ្រប់គ្រង ដូចជា គណៈកម្មាធិការគ្រប់គ្រងថ្នាក់រៀនតាមសាលារៀន និងសហគមន៍។ កម្មវិធីទាំងអស់ទាមទារឱ្យមានការចូលរួមពីសហគមន៍ ហើយត្រូវតែមានការយល់ព្រមពីគណៈកម្មាធិការ និងសាលាដើម្បីឱ្យមូលនិធិដំណើរការប្រកបដោយប្រសិទ្ធភាព។ មិនមានដែនកំណត់ចំពោះចំនួននៃការចូលរួមពីក្រុមគ្រួសាររបស់សិស្ស ហើយសម្រាប់អ្នកដែលមិនអាចបង់ប្រាក់បាន មិនចាំបាច់បង់ប្រាក់ទេ។

# ៥. សេចក្តីសន្និដ្ឋាន

បន្ទាប់ពីទទួលបាននូវ គំនិត ចំណេះដឹង បញ្ហាប្រឈម និងសំណូមពរដែលបានចែករំលែក ឡើងក្នុងសន្និសីទនេះ រំលេចឱ្យយើងឃើញថាវាគឺជាទំនួលខុសត្រូវរបស់យើងទាំងអស់គ្នា រួមទាំង ក្រសួងអប់រំ យុវជន និងកីឡា អង្គការសង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ រួបរួមគ្នាក្នុងការដោះស្រាយនូវរាល់បញ្ហាដែលបានលើកឡើង តាមរយៈការធ្វើបរិវត្តកម្ម បង្កើតប្រព័ន្ធអប់រំដែលធានាថាគ្មានកុមារត្រូវបានទុកចោល។

## ៥.១ បញ្ហាសំខាន់ៗដែលបានពិភាក្សា

សន្និសីទនេះបានផ្តល់នូវវេទិកាមួយដើម្បីស្វែងយល់ពីបញ្ហាប្រឈមក្នុងវិស័យអប់រំជាច្រើននៅកម្ពុជា ចាប់តាំងពីពីតម្រូវការសម្រាប់ការអនុវត្តបរិយាបន្ន ដល់ភាពចាំបាច់នៃការដោះស្រាយវិសមភាពធនធាន។ អ្នកចូលរួមទាំងអស់បានចូលរួមក្នុងការសន្ទនាអំពី៖

- សិទ្ធិទទួលបានការអប់រំប្រកបដោយគុណភាពសម្រាប់អ្នកសិក្សាទាំងអស់ រួមទាំងជនមានពិការភាព និងពីសហគមន៍ដែលខ្វះខាត។
- តម្រូវការបន្ទាន់នៃការលើកកម្ពស់សមត្ថភាពគ្រូបង្រៀន និងការអភិវឌ្ឍវិជ្ជាជីវៈ ដើម្បីបំពេញតម្រូវការចម្រុះរបស់សិស្ស។
- តួនាទីសំខាន់នៃយន្តការត្រួតពិនិត្យ និងវាយតម្លៃក្នុងការធានាការអនុវត្តគោលនយោបាយប្រកបដោយប្រសិទ្ធភាព និងគណនេយ្យភាព។
- ភាពចាំបាច់នៃការវិនិយោគដ៏រឹងមាំនៅក្នុងធនធានអប់រំ ហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារៈបរិក្ខារ ដើម្បីបង្កើតបរិយាកាសសិក្សាដែលអំណោយផល។
- ភាពចាំបាច់នៃការលើកកម្ពស់សមភាពយេនឌ័រក្នុងការអប់រំ និងការដោះស្រាយឧបសគ្គសង្គម-វប្បធម៌ដែលរារាំងដល់ការចូលរៀនរបស់ក្មេងស្រីក្នុងការសិក្សា។
- សារៈសំខាន់នៃការបង្កើនការផ្តល់ហិរញ្ញប្បទានការអប់រំសាធារណៈ ដើម្បីបង្កើនគុណភាពអប់រំសម្រាប់ទាំងអស់គ្នា ជាពិសេសសម្រាប់សាលារៀននៅតំបន់ដាច់ស្រយាល។

## ៥.២ អនុសាសន៍ និងវិធានការសំខាន់ៗ

ផ្អែកលើការពិភាក្សាទាំងនេះ ភាគីពាក់ព័ន្ធបានលើកឡើងនូវសំណុំនៃអនុសាសន៍ និងអន្តរាគមន៍ដែលអាចអនុវត្តបាន ក្នុងគោលបំណងជំរុញការផ្លាស់ប្តូរនៅក្នុងទិដ្ឋភាពអប់រំនៅកម្ពុជា៖

- ការអនុវត្តកម្មវិធីបណ្តុះបណ្តាលគ្រូឱ្យបានទូលំទូលាយ ដើម្បីបំពាក់ឱ្យអ្នកអប់រំនូវជំនាញ និងចំណេះដឹងដើម្បីគាំទ្រអ្នកសិក្សាចម្រុះប្រកបដោយប្រសិទ្ធភាព។
- ការពង្រឹងក្របខណ្ឌត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីតាមដានវឌ្ឍនភាព កំណត់គម្លាត និងជំរុញការសម្រេចចិត្តផ្អែកលើភស្តុតាងនៅគ្រប់កម្រិតទាំងអស់។

- ការវិនិយោគលើការបង្កើត និងផ្សព្វផ្សាយសម្ភារៈសិក្សា និងការបង្រៀនប្រកបដោយបរិយាប័ន្ន ដែលបំពេញតម្រូវការភាសា វប្បធម៌ និងការសិក្សាចម្រុះរបស់សិស្ស។
- ការតស៊ូមតិដើម្បីបង្កើនការបែងចែកថវិកាសាធារណៈ និងការកៀរគរធនធាន ដើម្បីធានាបាននូវមូលនិធិប្រកបដោយនិរន្តរភាពសម្រាប់គំនិតផ្តួចផ្តើមអប់រំ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាលារៀន។
- ការចូលរួមសហគមន៍ អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍ ក្នុងកិច្ចខិតខំប្រឹងប្រែងរួមគ្នា ដើម្បីលើកកម្ពស់វប្បធម៌នៃការសិក្សាពេញមួយជីវិត និងភាពជាម្ចាស់នៃសហគមន៍នៃការអប់រំ។

## ៥.៣ សេចក្តីអំពាវនាវ

### ៥.៣.១ សេចក្តីអំពាវនាវទៅកាន់ក្រសួងអប់រំ យុវជន និងកីឡា

- ដើម្បីលើកកម្ពស់លទ្ធភាពសមធម៌ និងលទ្ធផលសិក្សាប្រកបដោយគុណភាពសម្រាប់អ្នកសិក្សាទាំងអស់ ក្រសួងអប់រំ យុវជន និងកីឡា គួរតែផ្តល់អំណាចដល់រដ្ឋបាលស្រុក ក្នុងការលើកកម្ពស់លទ្ធភាពទទួលបានការអប់រំរបស់កុមារទាំងអស់ ជាពិសេសក្រុមដែលខ្វះខាត និងងាយរងគ្រោះ។ ក្រសួងអ.យ.ក ត្រូវតែគាំទ្រដល់អាជ្ញាធរមូលដ្ឋានក្នុងការប្រមូលទិន្នន័យស្តីពីកុមារពិការ និងលើកទឹកចិត្តដល់យុទ្ធនាការចុះឈ្មោះចូលរៀន ដោយផ្តោតលើកុមារនៅក្រៅសាលា។
- កាត់បន្ថយការបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិឱ្យតិចជាង ១០% ដោយអនុវត្តតាមខ្នាតប្រព័ន្ធព្រមានជាមុន ដើម្បីជួយដល់កុមារដែលមានហានិភ័យនៃការបោះបង់ការសិក្សា។ សាលារៀនត្រូវតែបង្កើតក្រុមចាំជួយគាំទ្រ ដើម្បីផ្តល់ជំនួយសង្គមដល់សិស្ស និងគ្រួសាររបស់ពួកគេ។ ក្រុមគាំទ្រអាចជាអង្គការសង្គមស៊ីវិល ដែលមានកម្មវិធីការងារសង្គម ហើយការគាំទ្រអាចជាការពង្រីកកម្មវិធីអាហារូបករណ៍សម្រាប់ជនពិការ។ ជាងនេះទៅទៀត គួរផ្តល់សមត្ថភាពឱ្យយុវជនក្នុងការរៀបចំអនាគត និងអាជីពក្នុងក្តីស្រមៃរបស់ពួកគេ ដោយអនុវត្តកម្មវិធីតម្រង់ទិសអាជីពនៅក្នុងសាលាចាប់ពីថ្នាក់ទី ៧ តទៅ។
- បង្កើនការគាំទ្រដើម្បីដាក់ឱ្យដំណើរការកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈជាបន្តទាំងក្រៅបណ្តាញ និងតាមអ៊ីនធឺណិត ដោយធ្វើការជាមួយអង្គការសង្គមស៊ីវិល ដើម្បីលើកកម្ពស់វេទិការ និងបង្កើតខ្លឹមសារដើម្បីកែលម្អវិធីសាស្ត្របង្រៀន។
- ត្រូវបង្កើនថវិកាអប់រំយ៉ាងហោចណាស់ ២០% នៃចំណាយជាតិ ឬ ៤% នៃផលិតផលក្នុងស្រុកសរុប (GDP)។ ម្យ៉ាងទៀតថវិកាសាលាគួរតែត្រូវបានបែងចែកដោយផ្អែកលើតម្រូវការរបស់សាលានីមួយៗ។

### ៥.៣.២ សេចក្តីអំពាវនាវទៅកាន់អង្គការសង្គមស៊ីវិល

- ប្រមូលធនធាន និងជំនាញផ្សេងៗ ដើម្បីគាំទ្រគំនិតផ្តួចផ្តើមនៅកម្រិតមូលដ្ឋានដែលផ្តល់សិទ្ធិអំណាចដល់សហគមន៍ សាលារៀន និងលើកកម្ពស់ការអនុវត្តការអប់រំបរិយាបន្ន។ ធនធានដែលទទួលបានទាំងនោះគួរតែត្រូវបានប្រើប្រាស់យ៉ាងល្អ ដើម្បីគាំទ្រដល់ការសម្រេចបាននូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាព ៤ និង ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០២៤-២០៣០ នាពេលខាងមុខ។

- គស្ទីមតិសម្រាប់ការវិនិយោគសាធារណៈដែលផ្តល់អាទិភាពដល់តម្រូវការរបស់ប្រជាជនដែលខ្វះខាត និងងាយរងគ្រោះ រួមទាំងជនមានពិការភាព និងជនជាតិភាគតិច។

### ៥.៣.៣ សេចក្តីអំពាវនាវទៅកាន់ដៃគូអភិវឌ្ឍ

- គាំទ្រ ក្រសួងអ.យ.ក ដើម្បីទទួលបានធនធានហិរញ្ញវត្ថុប្រកបដោយនិរន្តរភាព ដូចជាការបង្កើនចំណែកនៅក្នុងផលិតផលក្នុងស្រុកសរុប (GDP) ។
- ជំរុញភាពជាដៃគូ និងវេទិកាចែករំលែកចំណេះដឹង ដែលជួយសម្រួលដល់ការផ្លាស់ប្តូរការអនុវត្តល្អៗ ការច្នៃប្រឌិត និងមេរៀនដែលបានរៀននៅក្នុងកម្មវិធីអប់រំ។